SeeBeyondBorders

## គោលនយោបាយ

# គោលនយោបាយការពារកុមារ
# និងជនងាយរងគ្រោះ

ការផ្លាស់ប្តូរចាប់ផ្តើមពីការអប់រំ

# មាតិកា


**១. សេចក្តីផ្តើម និង បុព្វកថា ៣**

**២. គោលបំណងនៃគោលនយោបាយ ៣**

**៣. វិសាលភាពនៃគោលនយោបាយនេះ ៤**

**៤. គោលការណ៍ណែនាំ ៤**

**៥. និយមន័យ ៥**

- **កុមារនិងមនុស្សវ័យក្មេង ៥**
  - **ការរំលោភបំពាន ៥**
  - **កិច្ចការពារ ៦**
  - **ករណីយកិច្ចនៃការយកចិត្តទុកដាក់ ៦**
  - **កិច្ចការពារសុវត្ថិភាព ៦**
  - **ជនងាយរងគ្រោះ ៦**

**៦. ការជ្រើសរើស ការសម្រាំង និង ការណែនាំដល់បុគ្គលិក ៧**

**៧. ការអប់រំ និងការបណ្តុះបណ្តាលជាប្រចាំ ៨**

**៨. ការឆ្លើយតបនៅពេលដែលមានការរាយការណ៍ពីកុមារនិងមនុស្សវ័យក្មេង ៨**

**៩. ការថតរូប វីដេអូដែលមានកុមារ និងជនងាយរងគ្រោះចូលរួម/ ការប្រើប្រាស់រូបភាព ៩**

**១០. ការធ្វើការជាមួយដៃគូ ៩**

**១១. ការគ្រប់គ្រងគោលនយោបាយ ១០**

**ឧបសម្ព័ន្ធ ក៖ ក្រមសីលធម៌ក្នុងពេលការធ្វើការជាមួយកុមារ និងជនងាយរងគ្រោះ ១១**

**ទំនួលខុសត្រូវរបស់យើង ១១**

**ឧបសម្ព័ន្ធ ខ៖ អ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ និងភ្ញៀវទស្សនៈកិច្ចគម្រោង- វិធានបង្ការសុវត្ថិភាព ១៤**

**ឧបសម្ព័ន្ធ គ៖ ដំណើរការនៃការរាយការណ៍ ការគាំទ្រ និងការឆ្លើយតប ការរំលោភបំពានលើកុមារ ១៩**

**ឧបសម្ព័ន្ធ ឃ៖ ទំនាក់ទំនងលម្អិត អំពីភ្នាក់ងារការពារកុមារ ក្នុងប្រទេសកម្ពុជា ២៣**

គោលនយោបាយកិច្ចការពារកុមារ និងជនងាយរងគ្រោះ

## ១. សេចក្តីផ្តើម និងបុព្វកថា

អង្គការទស្សនៈឥតព្រំដែន(SeeBeyondBorders) គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ ដែលបានចុះបញ្ជីជាអង្គការសប្បុរសធម៌ នៅប្រទេសអូស្ត្រាលី និងអង់គ្លេស ហើយដំណើរការ និងចុះបញ្ជីក្នុងប្រទេសកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាល។ ទស្សនៈវិស័យរបស់យើងគឺ ផ្តល់អោយកុមារកម្ពុជា នូវលទ្ធភាពនៃការទទួលបានការបង្រៀន និងរៀនដោយមានគុណភាព នៅតាមសាលារៀន។

បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកចូលរួមរបស់អង្គការទស្សនៈឥតព្រំដែន ធ្វើការនៅក្នុងសាលារៀនជាមួយ នឹងគ្រូបង្រៀន កុមារ និង មនុស្សវ័យក្មេង ដូចច្នេះហើយទើបអង្គការទស្សនៈឥតព្រំដែនចាំបាច់ ត្រូវតែមាន គោលនយោបាយការពារកុមារ និងជនងាយរងគ្រោះច្បាស់លាស់ និងនីតិវិធីប្រកបដោយ ប្រសិទ្ធិភាពដែលអាចគ្រប់គ្រង តំបន់ប្រតិបត្តិការទាំងបីរបស់ SeeBeyondBorders ។

## ២. គោលបំណងនៃគោលនយោបាយ

អង្គការទស្សនៈឥតព្រំដែនបានប្តេជ្ញាចិត្ត ក្នុងការផ្តល់កិច្ចការពារកុមារ និងជនងាយរងគ្រោះអោយមានសុវត្ថិភាព រួចផុតពីការរំលោភបំពាន និងគ្រោះថ្នាក់ផ្សេងៗ ហើយគោលនយោបាយនេះ បានកំណត់ពីរបៀប ខំប្រឹងប្រែងដើម្បីកាត់បន្ថយ ហានិភ័យ ដូចជាគ្រោះថ្នាក់ ការរំលោភបំពាន ដែលកើតឡើងតាមបរិបទការងាររបស់យើង និងវិធីដែលយើងដោះស្រាយ ជាមួយឧប្បត្តិហេតុជាក់លាក់ ដែលត្រូវបានរកឃើញ។ ការខិតខំប្រឹងប្រែងរបស់ពួកយើងគឺដើម្បីពង្រឹង និងបង្កើនស្ថានភាពរស់នៅរបស់សហគមន៍ដែលយើងធ្វើការជាមួយ ដូចនេះ សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ និងជនងាយរងគ្រោះដែលទាក់ទងជាមួយបុគ្គលិក និងកម្មវិធីរបស់អង្គការទស្សនៈឥតព្រំដែន ជាការកង្វល់ដ៏ធំបំផុតរបស់យើង ។

អង្គការទស្សនៈឥតព្រំដែនបានទទួលស្គាល់និយមន័យនៃគោលការណ៍សុវត្ថិភាពដែលស្ថិតក្នុងបរិបទនៃកិច្ចការពារកុមារពីការមិនទទួលបានការព្យាបាលគ្រប់គ្រាន់ កង្វះនៃការបង្ការបញ្ហាសុខភាព និងការអភិវឌ្ឍកុមារ ហើយនិងធានាថាកុមារ រីកលូតលាស់ក្នុងកាលៈទេសៈដែលមានសុវត្ថិភាព ដែលគុណតម្លៃ ទាំងនេះជាគ្រឹះចំបងនៃគោលនយោបាយ។ សកម្មភាពនានាទាក់ទងនឹងកិច្ចការពារកុមារ ដែលបានកំណត់យ៉ាងសំខាន់ក្នុង គោលនយោបាយនេះគឺមានបំណងការពារទាំងកុមារ និងជនងាយរងគ្រោះទាំងឡាយ ដែលយើងបានកំណត់ថាពួកគេកំពុងរងគ្រោះ ឬស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឬកំពុងស្ថិតក្នុងគ្រោះអាសន្ន។

អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ថាហានិភ័យនៃការរំលោភបំពានលើកុមារ និងជនងាយរងគ្រោះ អាចកើតចេញពីបុគ្គលិកផ្ទាល់ ហើយយើងជឿជាក់ថា កត្តាដែលអាចកាត់បន្ថយធំបំផុតគឺតាមរយៈ ដំណើរការនៃការជ្រើសរើសបុគ្គលិកទាំងអស់។ គោលនយោបាយនេះគ្របដណ្តប់ លើការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ និងជនងាយរងគ្រោះ ការគ្រប់គ្រងហានីភ័យ ក្រមសីលធម៌ ការថតរូប វីដេអូកុមារ និងការគ្រប់គ្រងលើគោលនយោបាយ។ យើងក៏គាំទ្រទៅលើសិទ្ធិ សេចក្តីថ្លៃថ្នូរ និងសុខមាលភាពរបស់បុគ្គលិកផងដែរ ដោយលើកទឹកចិត្តអោយមានការចូលរួមយ៉ាងសកម្ម ក្នុងការចាត់ចែងពីសុវត្ថិភាព និងបរិយាកាសប្រកបដោយការគោរពគ្នា នៅ

ពេលចូលរួមជាមួយសកម្មភាពរបស់អង្គការទស្សនៈឥតព្រំដែន ដើម្បីកាត់បន្ថយហានិភ័យសំរាប់ពួកគេ និងអ្នកចូលរួមផ្សេងទៀត។

## ៣. វិសាលភាពគោលនយោបាយ

គោលនយោបាយនេះអនុវត្តចំពោះគ្រប់បុគ្គលិកទាំងអស់របស់អង្គការទស្សនៈឥតព្រំដែន៖

- **ក្រុមប្រឹក្សាភិបាល**
- **បុគ្គលិក និងអ្នកស្ម័គ្រចិត្តបច្ចុប្បន្ន**
- **អ្នកប្រឹក្សាខាងក្រៅ រឺ អ្នកដែលមានកិច្ចសន្យា (បានជួល រឺស្ម័គ្រចិត្ត)**
- **បុគ្គលិកកិច្ចសន្យា អង្គភាពដែលពាក់ព័ន្ធ និងសេវាផ្សេងៗ**
- **អ្នកចូលរួមក្នុងក្រុមគម្រោង**
- **អ្នកពាក់ព័ន្ធផ្សេងទៀត ឬអ្នកដែលធ្វើការក្នុងនាមជាអង្គការទស្សនៈឥតព្រំដែន**

គោលនយោបាយនេះក៏ត្រូវបានអនុវត្តផងដែរចំពោះ បុគ្គលផ្សេងៗ និងភាគីទីបី ដែលមានជាប់ទាក់ទង និង អង្គការទស្សនៈឥតព្រំដែន ដែលអាចមកទស្សនៈកិច្ច ការអនុវត្តសកម្មភាពគម្រោង (ដូចជាម្ចាស់ជំនួយ អង្គការដៃគូ អូស្ត្រាលី និង អង់គ្លេស រឺអ្នកផ្តល់សេវា) ទោះបីជាយ៉ាងណាក៏ដោយដំណើរការនៃការគ្រប់គ្រង អាចខុសប្លែក តាមរូបភាពជាក់ ស្តែង ដែលត្រូវបានផ្តល់អោយតាមរយៈការចូលរួមរបស់ពួកគេ។

## ៤. សេចក្តីណែនាំ នៃគោលនយោបាយ

គោលនយោបាយការពារកុមារនិង ជនងាយរងគ្រោះរបស់អង្គការទស្សនៈឥតព្រំដែនមានគោលការណ៍ណែនាំប្រាំដូចតទៅ៖

➢ <u>មិនមានការអត់អោនចំពោះការរំលោភបំពាននិងការកេងប្រវ័ញ្ច៖</u>

ការរំលោភបំពាន ឬសកម្មភាពផ្សេងទៀតដែលបង្កគ្រោះថ្នាក់ដល់កុមារ មនុស្សវ័យក្មេង និងជនងាយរងគ្រោះគឺមិនត្រូវបានអត់ឱនពីអង្គការទស្សនៈឥតព្រំដែនទេ សូម្បីតែការរក្សារូបភាព ឬការចូលមើលរូបភាព ឬវីដេអូពីកុមារដែលត្រូវគេរំលោភឬកេងប្រវ័ញ្ចផ្លូវភេទ។

➢ <u>ការទទួលស្គាល់ និងតម្កល់អត្ថប្រយោជន៍របស់កុមារ៖</u>

អង្គការទស្សនៈឥតព្រំដែនប្តេជ្ញាលើកកំពស់សិទ្ធិកុមារ ហើយទទួលស្គាល់ថាកុមារមួយចំនួនដូចជា កុមារពិការ និងកុមាររស់នៅក្នុងតំបន់ដែលរងគ្រោះដោយគ្រោះមហន្តរាយ (គ្រោះធម្មជាតិឬដែលមានជម្លោះ) គឺងាយរងគ្រោះជាពិសេស។

➢ <u>ស្មារតីរួមទទួលខុសត្រូវចំពោះកិច្ចការពារកុមារ និងជនងាយរងគ្រោះ៖</u>

ដើម្បីគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពចំពោះកុមារ និងជនងាយរងគ្រោះ អង្គការទស្សនៈឥតព្រំដែនតម្រូវឱ្យមានការគាំទ្រនិងការសហការយ៉ាងសកម្មពីបុគ្គលិកទាំងអស់។ បុគ្គលិករបស់អង្គការទស្សនៈឥតព្រំដែន ត្រូវតែគោរពតាមគោលនយោបាយនេះ ហើយនឹងទទួលខុសត្រូវចំពោះការគោរពតាមច្បាប់នេះ។

➢ <u>ការប្រើវិធីសាស្ត្រគ្រប់គ្រងហានិភ័យ៖</u>

ការគ្រប់គ្រងដោយប្រុងប្រយ័ត្នអាចកាត់បន្ថយឧប្បត្តិហេតុនៃការរំលោភបំពានលើកុមារ និងជនងាយរងគ្រោះដែលជាប់ទាក់ទងនឹងសកម្មភាពជំនួយ។ គោលនយោបាយនេះណែនាំអំពីយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយហានិភ័យមួយចំនួនដែលត្រូវបានទទួលស្គាល់ចំពោះកុមារ និងជនងាយរងគ្រោះ។

➢ <u>ករណីយកិច្ចយកចិត្តទុកដាក់៖</u>

អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ទំនួលខុសត្រូវករណីយកិច្ចរបស់ខ្លួនដែលត្រូវយកចិត្តទុកដាក់ ហើយអនុវត្តគ្រប់ជំហានដែលសមស្របដើម្បីការពារសុវត្ថិភាពកុមារនិងជនងាយរងគ្រោះនៅក្នុងកម្មវិធីរបស់ខ្លួន។

ក្នុងនាមជាអង្គភាពទទួលជំនួយពីDFAT អង្គការទស្សនៈឥតព្រំដែនក៏ប្រើស្តង់ដារអប្បបរមាទាំង៩ស្តីពីការការពារកុមាររបស់DFAT ដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធ«ឃ» សម្រាប់ជាមូលដ្ឋានក្នុងការតាក់តែងគោលនយោបាយនេះ និងនីតិវិធីពាក់ព័ន្ធ។

# ៥. និយមន័យ

## <u>កុមារ និងមនុស្សវ័យក្មេង៖</u>

យោងតាមអនុសញ្ញា អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩, អង្គការទស្សនៈឥតព្រំដែនកំណត់ថា កុមារ និងមនុស្សវ័យក្មេង គឺជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ បើទោះបីមានច្បាប់ម្ចាស់ប្រទេសកំណត់និយមន័យផ្សេងទៀតក៏ដោយ។

## <u>ការរំលោភបំពាន</u>

ការរំលោភបំពានរាប់បញ្ចូលទាំងការរំលោភបំពានផ្នែករូបរាងកាយ ស្មារតី រឺផ្លូវចិត្ត ការព្រងើយកន្តើយ ការកេងប្រវ័ញ្ចរឺការរំលោភបំពានផ្លូវភេទ។ ទាំងក្មេងប្រុស ក្មេងស្រី ស្ត្រីនិងបុរស អាចក្លាយខ្លួនជាជនរងគ្រោះបណ្តាលមក ពីការរំលោភបំពាន ហើយការរំលោភបំពានផ្តល់ផលអាក្រក់ដល់ កុមារ ជនងាយរងគ្រោះ បុរស ស្ត្រីនិងកុមារផ្សេងទៀត។

**ការរំលោភបំពានផ្លូវកាយ៖** នៅពេលដែលបុគ្គលណាមួយមានបំណងធ្វើអោយកុមារ និងជនងាយរងគ្រោះ ផ្សេងទៀតរបួស គំរាមធ្វើអោយរបួស។ ទម្រង់ទាំងនេះអាចជា ៖ ទះ វាយ ដាល់ ចាប់ក្រវី ទាត់ ដុត ក្តិច...។

**ការរំលោភបំពានផ្លូវចិត្ត៖** នៅពេលដែលកុមារ រឺជនងាយរងគ្រោះ ទទួលរងនូវការ បដិសេធម្តងហើយម្តងទៀត ឬសម្លុតដោយពាក្យសម្តី ឬមធ្យោបាយផ្សេងទៀត។ ទម្រង់ទាំងនេះអាចជា៖ ជេរប្រមាថ, ស្រែក, គំរាម, ទុកចោល, សើចចំអក ដោយប្រើ កាយវិការ និងសំដី...។

**ការរំលោភបំពានផ្លូវភេទ៖** នៅពេលដែល មនុស្សពេញវ័យ រឺមនុស្សជំទង់ ដែលមានអំណាចខ្លាំងជាង កុមារ ពួកគេប្រើអំណាចរបស់ខ្លួន ពាក់ព័ន្ធ រឺជំរុញអោយមានទំនាក់ទំនងផ្លូវភេទជាមួយកុមារ។ អំណាចទាំងនេះអាចប្រើ ក្នុងរូបភាពជា សំដី កាយវិការ រឺ ការប្រើអារម្មណ៍។ សកម្មភាពផ្លូវភេទរាប់បញ្ចូល ដូចជា៖ ការប៉ះពាល់ដោយមិនសមរម្យ, បំរើដោយមិនសមរម្យ, ផ្សព្វផ្សាយរូបភាពអាសអាភាសន៍របស់កុមារ, មានទំនាក់ទំនងផ្លូវភេទជាមួយកុមារ។

**ការព្រងើយកន្តើយ៖** នៅពេលដែលមនុស្សពេញវ័យមិនអាចផ្តល់អោយនូវអ្វីដែលជាលក្ខខណ្ឌពិសេស សំរាប់ការអភិវឌ្ឍ និងសុខមាលភាពផ្នែករូបរាងកាយ ប្រាជ្ញាស្មារតី រឺក៏មិនបានលើកឡើងនូវបញ្ហាជុំវិញសុខភាព និងជម្ងឺ របស់កុមារ។

**ការធ្វើបាប៖** គឺជាការដាក់វិន័យ រឺកែតម្រូវ កុមារ រឺជនរងគ្រោះដោយឥរិយាបទមិនសមរម្យធ្ងន់ធ្ងរ តម្រូវអោយកុមារធ្វើការលើសលប់ រឺតិចតួចខ្លាំង បន្ទាបបន្ថោកដោយប្រើកំលាំងប្រឆាំងនឹងកុមារ រឺទម្រង់ណាមួយនៃអំពើរព្រៃផ្សៃ ចំពោះកុមារ។

## <u>កិច្ចការពារ</u>

កិច្ចការពារគឺជាសកម្មភាព រឺការផ្តួចផ្តើមថ្មី ដើម្បីការពារកុមារនិងជនងាយរងគ្រោះអោយរួចផុតពីគ្រប់ទម្រង់នៃគ្រោះថ្នាក់ ជាពិសេសគឺ ការរំលោភបំពាន។ កិច្ចការពារកុមារគឺជា សកម្មភាពដែលអាចជួយ អោយសំរេច បាននូវសុខសុវត្ថិភាពរបស់កុមារ។

## <u>ករណីយកិច្ចនៃការយកចិត្តទុកដាក់</u>

ករណីយកិច្ចនៃការយកចិត្តទុកដាក់គឺជាផ្នត់គំនិតសំខាន់នៃច្បាប់ដែលឆ្ពោះទៅកាន់ទំនួលខុសត្រូវរបស់អង្គភាពទាំងមូល ដើម្បីផ្តល់ចំពោះកុមារនិងជនងាយរងគ្រោះ ដែលចូលរួមក្នុងសកម្មភាពរបស់កម្មវិធី របស់អង្គការទស្សនៈឥតព្រំដែន ក្នុងកំរិតសមល្មមនៃការការពារពី គ្រោះថ្នាក់នៃកុមារ។ វាជាករណីយកិច្ចរបស់អង្គភាពដែល ត្រូវ ធានាថាគ្មានការធ្វេសប្រហែស ពាក់ព័ន្ធនិងកិច្ចការពារកុមារ និងជនងាយរងគ្រោះ អំពីគ្រោះថ្នាក់ដែល យើងអាច ដឹងមុន។

## <u>ការបង្ការហានីភ័យ</u>

ការបង្ការហានីភ័យ មានន័យទូលំទូលាយ ជាងកិច្ចការពារកុមារ។ វាគឺជាដំណើរការនៃការពារកុមារ និង ជនងាយរងគ្រោះឱ្យចៀសផុតពីការរំលោភបំពាន រឺ ព្រងើយកន្តើយ ការមិនទទួលបានការព្យាបាលគ្រប់គ្រាន់, បង្ការកង្វះខាតនៃការគិតគូរបញ្ហាសុខភាព និងការអភិវឌ្ឍរបស់កុមារ ដើម្បីធានាថាកុមារ រីកលូតលាស់ក្នុងកាលៈទេសៈ ដែលមានសុវត្ថិភាព និងការយកចិត្តទុដាក់ដែលមានប្រសិទ្ធភាព ដែលអាចអោយពួកគេមានឱកាសទូលំទូលាយក្នុងការផ្លាស់ប្តូរជីវិតរបស់ពួកគេ។

កត់ចំណាំថាគោលបំណងនៃគោលនយោបាយនេះ «**ការបង្ការហានីភ័យ**»សំដៅទៅលើសកម្មភាពដែលធ្វើឡើងដោយ អង្គការ ទស្សនៈឥតព្រំដែន ដើម្បីបង្ការគ្រោះថ្នាក់ ក្នុងករណីអាក្រក់បំផុតដែលបង្កដោយសហការី របស់អង្គការទស្សនៈឥតព្រំដែន នោះយើងនឹងចូលខ្លួនអន្តរាគមន៍ដោយផ្ទាល់។ វាមិនខុសប្លែកពី គោលការណ៍ ដែលបានដាក់បញ្ចូលទៅ ក្នុងគោលនយោបាយបង្ការហានីភ័យកុមារ និងជនងាយរងគ្រោះ នោះទេ ដោយគ្រាន់តែ គោលនយោបាយការពារកុមារ និងជនងាយរងគ្រោះ(លើកនេះ) បានពង្រីកវិសាលភាពមិនត្រឹមតែការតាមដានករណីប៉ុណ្ណោះទេ គឺមានវិធានការបង្ការ ដោយរាប់បញ្ចូលទាំងក្នុងអង្គភាព និងទីសារធារណៈ។ ដូចច្នេះគោលនយោបាយការពារកុមារ បានរួមបញ្ចូល គ្រប់ចំណុចទាំងអស់របស់កិច្ចការពារសុវត្ថិភាពដែលបានចង្អុលបង្ហាញក្នុងគោលនយោបាយបង្ការហានីភ័យ។

## <u>ជនងាយរងគ្រោះ</u>

ជនងាយរងគ្រោះអាចកំណត់ថាជាមនុស្សដែលរងគ្រោះពីការរលោភបំពាន ក្រោមហេតុផលអាយុ សុខភាព សមត្ថភាពផ្លូវកាយ ផ្លូវចិត្ត ស្ថានភាពសេដ្ឋកិច្ច និងទំហំអាស្រ័យលើតម្រូវការមូលដ្ឋានរបស់ពួកគេ។ វាមិនបានកំណត់ថាត្រូវតែជាកុមារនោះទេ ព្រោះអាចរាប់បញ្ចូលទាំង មនុស្សពេញវ័យដែលចូលរួមនៅក្នុងសកម្មភាពកម្មវិធីរបស់អង្គការ ទស្សនៈឥតព្រំដែន។

## ៦. ការជ្រើសរើស ការសម្រាំង និង ការណែនាំដល់បុគ្គលិក

ការជ្រើសរើស និងសម្រាំងបុគ្គលិក ឆ្លុះបញ្ចាំងការប្តេជ្ញាចិត្ត ក្នុងកិច្ចការពារកុមារ និងជនងាយរងគ្រោះផ្សេងទៀត ដោយធានានូវភាពសមស្រប នៃនីតិវិធី និងការពិនិត្យ ដែលត្រូវបានដាក់អោយប្រើប្រាស់ ដើម្បីមានលទ្ធភាពជ្រើសចេញបុគ្គលដែលមិនសក្តិសមក្នុងការធ្វើការជាមួយកុមារ និងជនងាយរងគ្រោះ ហើយជ្រើសយកតែអ្នកណាដែល អាចធានា សុវត្ថិភាព និងអាចចែករំលែកនូវ គុណតម្លៃ និងការប្តេជ្ញាចិត្ត របស់អង្គការទស្សនៈឥតព្រំដែន ក្នុងការការពារក្រុមនេះ។

អង្គការទស្សនៈឥតព្រំដែន មាននីតិវិធីដ៏រឹងមាំ ស្តីអំពីដំណើរការជ្រើសរើសបុគលិកទាំងអស់ (ដូចដែលបានកំណត់ខាងលើ)។ ការប្តេជ្ញាចិត្តជាមូលដ្ឋាន របស់អង្គការទស្សនៈឥតព្រំដែន នៅក្នុងដំណើរការជ្រើសរើសបុគលិកមានដូចខាងក្រោមៈ

- លិខិតត្រួតពិនិត្យបទល្មើសព្រហ្មទណ្ឌ មុនពេលចូលធ្វើការ ឫលិខិតផ្លូវការស្របច្បាប់ដែលអាចបញ្ជាក់អំពីអាកប្បកិរិយា ក្នុងករណីមិនអាចរកលិខិតថ្កោលទោសបទល្មើសព្រហ្មទណ្ឌ ឫលិខិតនេះមិនគួរអាចទុកចិត្តបាន។
- យ៉ាងតិចណាស់ត្រូវមានការ ពិនិត្យដោយផ្ទាល់មាត់ពីសាក្សី ពីរនាក់ ដោយរាប់បញ្ចូលទាំងសំណួរដែលពាក់ព័ន្ធនិងឧប្បត្តិហេតុ ដែលកើតឡើងចំពោះកុមារ និងជនងាយរងគ្រោះ ដោយការយកចិត្តទុកដាក់។
- សំណួរពាក់ព័ន្ធនិង ឥរិយាបថដែលពាក់ព័ន្ធនឹងកុមារ

ដំណើរការទាំងនេះគឺត្រូវបាន ដាក់ជាឯកសារ នៅក្នុងនីតិវិធីនៃការជ្រើសរើសបុគ្គលិក ដែលរក្សានៅក្នុងតំបន់គ្រប់គ្រងឯកសារក្នុងអង្គភាព។

គ្មានបុគ្គលិកដែលមានអាយុក្រោម១៨ ឆ្នាំដែលត្រូវបានបំរើការក្នុងអង្គការទស្សនៈឥតព្រំដែនឡើយ ទោះជាមានសមត្ថភាព យ៉ាងណាក៏ដោយ។ អាចមានមនុស្សមួយចំនួនដែលត្រូវបានណែនាំអំពីកម្មវិធីនៅកន្លែងអនុវត្តសកម្មភាពរបស់កម្មវិធី ដូចជាក្រុមគម្រោង ដោយពួកគេ និងត្រូវមានវត្តមានមើលការខុសត្រូវដោយមនុស្សពេញវ័យទៅលើ ឥរិយាបថ រឺអាកប្បកិរិយារបស់ពួកគេផ្ទាល់។

## ៧. ការអប់រំ និង និងការបណ្តុះបណ្តាលជាប្រចាំ

យើងផ្តល់ការអប់រំ និងបង្រៀនដើម្បីលើកកំពស់ការយល់ដឹងអំពីកិច្ចការពារកុមារ និងការប្រព្រឹត្តទៅកាន់ជនងាយរងគ្រោះផ្សេងទៀត នៅក្នុងបរិបទនៃទំនួលខុសត្រូវរបស់អង្គការទស្សនៈឥតព្រំដែន  ទៅដល់បុគ្គលិកក្នុងកំឡុងវគ្គតម្រង់ទិស ណែនាំអំពីអង្គភាព និងកម្មវិធី ទោះបីជាស្ថិតក្នុងបរិបទដែលមានម្ចាស់ជំនួយ និងភ្ញៀវ មកធ្វើទស្សនៈ

កិច្ចតែម្តងក៏ដោយ (សូមមើលឧបសម្ព័ន្ធ ខ ស្តីពីអ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ និងអ្នកផ្សេងទៀតដែលមកទស្សនកិច្ចកម្មវិធី- វិធានការធានាសុវត្ថិភាព)។ វគ្គបណ្តុះបណ្តាលត្រូវបានដាក់បញ្ចូលក្នុង គោលនយោបាយការពារកុមារ និងជនងាយរគ្រោះ របស់អង្គការទស្សនៈឥតព្រំដែន រាប់បញ្ចូលទាំងការកត់ត្រា និងនីតិវិធីនៃការរាយការណ៍ ហើយបុគ្គលិកតម្រូវអោយចុះហត្ថលេខា និងប្រកាសការយល់ព្រមអនុវត្តគោលនយោបាយការពារកុមារនិងជនងាយរងគ្រោះ។ វគ្គរំលឹកឡើងវិញនឹងត្រូវធ្វើឡើងរៀងរាល់ឆ្នាំ រឺនៅពេលដែលមានការផ្លាស់ប្តូរ ឬកែប្រែ គោលនយោបាយ នីតិវិធីកត់ត្រាករណី ឬនីតិវិធីនៃការរាយការណ៍របស់អង្គការទស្សនៈឥតព្រំដែន។

<u>ការគ្រប់គ្រងហានិភ័យនៃអ្នកទទួលផលជាកុមារនិងជនងាយរងគ្រោះ</u>

អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ថាការរំលោភបំពាន គឺជាហានីភ័យប្រឈមដោយអង្គការទាំងអស់ដែលធ្វើការជាមួយកុមារ និងជនងាយរងគ្រោះ។ ហានិភ័យអាចកើតមានឡើងចំពោះជនងាយរងគ្រោះ ជាពិសេស នៅពេលអង្គការដែលអនុវត្តសកម្មភាពតាមតំបន់ដាច់ស្រយាល ទីជនបទ រឺតំបន់ក្រីក្រ។ អង្គការ  ទស្សនៈឥតព្រំដែនកំណត់ហានិភ័យទាំងនេះ ដែលកើតឡើងក្នុងកំរិតគំរោង ឬកម្មវិធី តាមរយៈការវាយតម្លៃហានិភ័យ។ ការវាយតម្លៃហានិភ័យនេះកំណត់៖ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើង (ឧទាហរណ៍ ដូចជាប្រភេទនៃហានិភ័យ), លទ្ធភាពនៃការកើតឡើងនូវហានិភ័យ កំរិតនៃផលប៉ះពាល់ បើសិនជាព្រឹត្តការណ៍នោះកើតឡើងពិតមែន ព្រមទាំងដាក់ចេញវិធានបង្ការការពារ។ នីតិវិធីគ្រប់គ្រង និងវាយតម្លៃហានិភ័យ ត្រូវបានដាក់បញ្ចូលជាទូទៅក្នុងវដ្តនៃការគ្រប់គ្រងគំរោងនិងបន្តដោះស្រាយដោយការគិតឆ្លុះបញ្ចាំងជាមូលដ្ឋាន។

## ៨. ការឆ្លើយតបទៅនឹងការរាយការណ៍ របស់កុមារ និងមនុស្សវ័យក្មេង

អង្គការទស្សនៈឥតព្រំដែន នឹងឆ្លើយតបយ៉ាងហ្មត់ចត់នូវរាល់កង្វល់ដែលបានលើកឡើង ហើយធានាថា រាល់ភាគីពាក់ព័ន្ធទាំងអស់ នឹងត្រូវបានប្រព្រឹត្តិយ៉ាងយុត្តិធម៌ និងដោយមិនមានការរើសអើង ឬបុរេវិនិច្ឆ័យឡើយ។ រាល់ការរាយការណ៍ និងត្រូវដោះស្រាយដោយវិជ្ជាជីវៈត្រឹមត្រូវ រក្សារការសម្ងាត់ និងឆាប់បំផុត។

រាល់របាយការណ៍ធ្វើឡើងដោយបំណងសុចរិត គឺជាការគិតគូផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ និងមនុស្សវ័យក្មេងផ្សេងទៀត ទោះបីជាលទ្ធផលនៃការស៊ើបអង្កេតនឹងបង្ហាញយ៉ាងម៉េចក៏ដោយ។  អង្គការទស្សនៈឥតព្រំដែននឹងធានាអត្ថប្រយោជន៍នៃអ្នករាយការណ៍ អំពីករណីរំលោភបំពានលើកុមារ ហើយពួកគេត្រូវទទួលបានការការពារដូចមានចែងនៅក្នុង គោលនយោបាយស្តីពីអ្នករាយការណ៍ ។ សិទ្ធិ និងសុខុមាលភាព របស់កុមារ និងមនុស្សវ័យក្មេងគឺជារឿងសំខាន់ដែលគេគិតមុនគេបង្អស់។ យើងខំប្រឹងប្រែងការពារសិទ្ធិ និងសុវត្ថិភាព កុមារនិងមនុស្សវ័យក្មេងក្នុងកំឡុងការស៊ើបអង្កេតពីដើមដល់ចប់។

នៅពេលដែលកុមារ ឬមនុស្សវ័យក្មេងរាយការណ៍ថា ពួកគេផ្ទាល់ត្រូវបានគេរំលោភបំពាន វាសំខាន់ណាស់ដែលត្រូវគិតគូដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

- ពួកគេមានអារម្មណ៍ខ្លាច គិតថាខ្លួនឯងមានកំហុស អាម៉ាស់ ផ្លូវចិត្តទន់ខ្សោយ។ ពេលទទួលរបាយការណ៍ អ្នកអាចនឹងមានអារម្មណ៍ច្រឡោត ស្អប់ខ្ពើម ក្រៀមក្រំ ខឹង និងមានពេលខ្លះអត់ជឿ។

- ប្រសិនបើឃើញថាកុមារស្ថិតក្នុងស្ថានភាពត្រូវគេរំលោភបំពាន លទ្ធផលយ៉ាងណាក៏ដោយ កុមារនោះត្រូវតែទទួលយកចិត្តទុកដាក់ជួយអោយហ្មត់ចត់។
- វាសំខាន់ណាស់សម្រាប់អ្នកក្នុងការធ្វើខ្លួនអោយស្ងប់ស្ងៀម និងគ្រប់គ្រងស្ថានការណ៍ដោយស្មារតីនឹងនរ ដើម្បីធានាថាយើងអាចធ្វើអ្វីម្យ៉ាងជួយឱ្យកុមារ និងមនុស្សវ័យក្មេងមានសុវត្ថិភាព។
- នៅពេលដែលកុមារ ឬមនុស្សវ័យក្មេងបង្ហាញប្រាប់អ្នកថាពួកគេត្រូវបានគេធ្វើឱ្យមានគ្រោះថ្នាក់ អ្នកអាចបង្ហាញការយកចិត្តទុក្ខដាក់ចំពោះកុមារ និងមនុស្សវ័យក្មេងតាមរយៈ៖
    - ស្តាប់ដោយការយកចិត្តទុកដាក់
    - ប្រាប់កុមារ ឬមនុស្សវ័យក្មេងថា អ្នកជឿលើពួកគេ
    - ប្រាប់កុមារ ឬមនុស្សវ័យក្មេងថា វាមិនមែនជាកំហុសរបស់ពួកគេទេ ហើយវាមិនមែនជាទំនួលខុសត្រូវរបស់អ្នកលើការរំលោភបំពាននេះនោះទេ។
    - ប្រាប់កុមារ និងមនុស្សវ័យក្មេងថា អ្នករីករាយនៅពេលដែលគាត់ទុកចិត្ត ប្រាប់រឿងនេះដល់អ្នក
- អ្នកនឹងមិនអាចជួយកុមារ ឬមនុស្សវ័យក្មេងបានទេប្រសិនបើអ្នកៈ
    - សន្យាជាមួយនិងកុមារនូវអ្វីដែលមិនអាចធ្វើបាន ដូចជាថានឹងមិនប្រាប់រឿងនេះដល់អ្នកណា
    - បង្ខំអោយកុមារប្រាប់អ្នកអំពីរឿងលំអិតទាក់ទងនឹងការរំលោភបំពាន។ តួនាទីរបស់អ្នកគឺស្តាប់ នូវអ្វីដែលកុមារចង់ប្រាប់អ្នក មិនមែនធ្វើការស៊ើបអង្កេតនោះទេ (ប្រយ័ត្នចំពោះសំណួរនាំមុខ ដែលនាំអោយមានភាពលំអៀងចំពោះការស៊ើបអង្កេតនៅពេលក្រោយ)។
    - ការពិភាក្សាអំពីស្ថានភាពរបស់កុមារ នឹងមនុស្សវ័យក្មេង ជាមួយមនុស្សដែលមិនពាក់ព័ន្ធ
- ប្រសិនបើមានការរាយការណ៍មកអ្នកដែលជាបុគ្គលិក ឬអ្នកស្ម័គ្រចិត្ត គឺត្រូវធ្វើទៅតាមគោលការណ៍នៃដំណើរការការរាយការណ៍ ការគាំទ្រ និងការឆ្លើយតប ដែលមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ "គ"។

## ៩. ការថតរូប ឬវីដេអូជាមួយកុមារនិង ជនងាយរងគ្រោះ និងការប្រើប្រាស់រូបទាំងនោះ

ដំណើរការទាំងនេះគឺត្រូវបានរក្សាទុកនៅក្នុងគោលនយោបាយស្តីពី រូបភាព និង គោលនយោបាយទំនាក់ទំនង និងបង្ហាញនៅក្នុង ឧបសម្ព័ន្ធ "ក" ក្រមសីលធម៌ក្នុងការធ្វើការជាមួយកុមារ និងជនងាយរងគ្រោះ។

## ១០. ការរាយការណ៍

វាជាការការតម្រូវចាំបាច់ដែលថាគ្រប់បុគ្គលរបស់អង្គការទស្សនៈឥតព្រំដែន(ដូចបានចែងក្នុងចំណុច៣ខាងលើ) ត្រូវរាយការណ៍ភ្លាមៗនូវរាល់ករណីសង្ស័យ ចោទប្រកាន់ ឬមានភស្តុតាងជាក់ស្តែងស្តីពីការកេងប្រវ័ញ្ច ការរំលោភលើកុមារ ឬការមិនអនុលោមតាមគោលនយោបាយ ទៅកាន់ជនបង្គោលបង្ការហានីភ័យ (Safeguarding Focal Point) ឬជនដែលសក្តិសមបំផុតផ្សេងទៀតដូចដែលមានចែងក្នុងឧបសម្ព័ន្ធ «គ»។

បន្ទាប់មក អង្គការទស្សនៈឥតព្រំដែនមានកាតព្វកិច្ចរាយការណ៍នូវរាល់រឿងករណីសង្ស័យ ចោទប្រកាន់ ឬមានភស្តុតាងជាក់ស្តែង ទៅកាន់ម្ចាស់ជំនួយមួយចំនួនក្នុងប្រទេសអូស្ត្រាលី ចក្រភពអង់គ្លេស និងអៀរឡង់។ សេចក្តីលម្អិតអំពីកាតព្វកិច្ចរាយការណ៍នេះមានចែងក្នុងឧបសម្ព័ន្ធ «គ» ហើយត្រូវបានចាត់ចែងដោយប្រធានផ្នែកអនុលោម (Compliance Manager)។

## ១១. ការបំពានគោលនយោបាយ

អង្គការទស្សនៈឥតព្រំដែន ទទួលយកដោយប្រាកដប្រជានូវរាល់ការព្រួយបារម្ភ ឬនិងរបាយការណ៍ស្តីពីការការរំលោភកុមារ ឬការមិនអនុលោមគោលនយោបាយ ហើយនឹងស៊ើបអង្កេត និងចាត់សកម្មភាពអន្តរគមន៍យ៉ាងហ្មត់ចត់លើករណីទាំងនេះ។

អង្គការទស្សនៈឥតព្រំដែន នឹងប្រើសិទ្ធិរបស់ខ្លួនក្នុងការបណ្តេញចេញ ឬដកមនុស្សរបស់អង្គការទស្សនៈឥតព្រំដែន នៅពេលពិចារណាថាបុគ្គលនោះបង្ហាញចេញនូវហានីភ័យដែលមិនអាចទទួលយកបានចំពោះសុវត្ថិភាព និងសុខុមលភាពរបស់កុមារនិងមនុស្សងាយរងគ្រោះ។ នេះឆ្លុះបញ្ចាំងអំពីគោលការណ៍គោលនយោបាយស្តីពីការមិនអត់ឱនចំពោះបទល្មើសរំលោភឬកេងប្រវ័ញ្ច។ បើពិចារណាឃើញថាចាំបាច់ អង្គការទស្សនៈឥតព្រំដែននឹងព្យួរបុគ្គលនោះ ឬបញ្ជូនទៅកាន់តួនាទីផ្សេងបណ្តោះអាសន្នក្នុងកំឡុងការស៊ើបអង្កេត។

អង្គការទស្សនៈឥតព្រំដែន រក្សាសិទ្ធិចបារបញ្ចប់កិច្ចសន្យាការងារ បដិសេធចូលរួមកិច្ចការជាមួយបុគ្គល ឬទាមទារឱ្យមានការជំនួសបុគ្គលនោះ ប្រសិនបើមិនបានធ្វើលិខិតកត់ត្រាបទឧក្រិដ្ឋ(លិខិតថ្កោលទោស) ឬមិនអាចធ្វើបាន ចំពោះតួនាទីដែលបង្ហាញថាត្រូវធ្វើការជាមួយកុមារ ឬមានការទំនាក់ទំនងផ្ទាល់ជាមួយកុមារ។

## ១២. ការធ្វើការជាមួយដៃគូ

ដោយគោរពការចាត់ចែងជាមួយនឹងដៃគូដូចនិយមន័យដែលបានកំណត់នៅក្នុង*គោលនយោបាយស្តីពី ការធ្វើការសហការជាមួយនឹងដៃគូ* និងនិយមន័យផ្សេងទៀតស្តីពីដៃគូ ដែលមានន័យទូទៅថាសកម្មភាពណាមួយដែលរួមគ្នាបំពេញការងារឱ្យ ឬក៏ធ្វើការតំណាងឱ្យ អង្គការទស្សនៈឥតព្រំដែន យើងដាក់ចេញគោលការណ៍អនុវត្តដែលទាក់ទងទៅនឹង គោលនយោបាយកិច្ចការពារកុមារ និងជនងាយរងគ្រោះ និងជាពិសេសគោលការណ៍នេះទាក់ទងទៅនឹងការការពារ និងកិច្ចបង្ការសុវត្ថិភាពដល់កុមារ និងជនងាយរងគ្រោះ សម្រាប់អនុវត្តដូចតទៅ៖

- បញ្ជាក់អោយបានច្បាស់នៅពេលដែល អង្គការទស្សនៈឥតព្រំដែនធ្វើកិច្ចសន្យាជាមួយបុគ្គលផ្សេង បុគ្គលឬអង្គភាពធ្វើកិច្ចសន្យាធ្វើការជាដៃគូ រាប់បញ្ចូលទាំងដៃគូដែលទទួលគំរោងទៅអនុវត្ត ដែលមានការពាក់ព័ន្ធជាមួយ នឹងកុមារ និងជនងាយរងគ្រោះ ត្រូវស្របតាមគោលនយោបាយស្តីពីការធ្វើការជាមួយដៃគូ និង ត្រូវតែធានាថា ដៃគូពាក់ព័ន្ធ មានដំណើរការ និងនីតិវិធី ដែលយ៉ាងហោចណាស់មានកំរិតប្រហែលគ្នា ទៅនឹងគោលនយោបាយកិច្ចការពារកុមារនិងជនងាយរងគ្រោះ។
- បើសិនជាដៃគូមិនមានគោលនយោបាយ និងនីតិវិធី ស្រដៀងគ្នា អង្គការទស្សនៈឥតព្រំដែន អាចមិនសហការ ឬក៏ជួយពួកគេដោយការកសាងសមត្ថភាព ហើយណែនាំពីយន្តការកិច្ចការពារកុមារចាំបាច់ មុនពេលចាប់ផ្តើមអនុវត្តគម្រោង។

## ១៣. ការគ្រប់គ្រងគោលនយោបាយ

គោលនយោបាយនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលអូស្រ្តាលី និងសមាជិកក្រុមប្រឹក្សារបស់ទីតាំងស្ថាប័នប្រទេសផ្សេងទៀតដូចមានរៀបរាប់ខាងក្រោម៖

វិសោធនកម្ម និង/ឬការអភិវឌ្ឍនៃគោលនយោបាយនេះ តែងត្រូវបានស្នើទៅដល់ក្រុមប្រឹក្សាភិបាល តាមកាលៈទេសៈជាក់ស្តែងតាមរយៈក្រុមអ្នកដឹកនាំ នៃអង្គការទស្សនៈឥតព្រំដែន។ ការពិនិត្យឡើងវិញជាផ្លូវការ នឹងធ្វើមុនផុត កំណត់រយៈពេល ៣ឆ្នាំ ចាប់ពីពេលដែលក្រុមប្រឹក្សាភិបាលបានចុះហត្ថលេខា។ ការកែប្រែតូចតាចអាចត្រូវបានអនុម័តដោយនាយកប្រតិបត្តិមុនថ្ងៃផុតកំណត់បាន ហើយសំណើការកែប្រែព័ត៌មានអំពីសាវតា ឬនីតិវិធីប្រតិបត្តិគោលនយោបាយអាចត្រូវបានអនុម័តដោយអនុគណៈកម្មការដែលពាក់ព័ន្ធ។

| លេខយោងឯកសារ | ប្រភេទឯកសារ | កាលបរិច្ឆេទអនុម័តដោយក្រុមប្រឹក្សាភិបាលអូស្រ្តាលី | កំណត់ហេតុយោង | កាលបរិច្ឆេទអនុម័តដោយក្រុមប្រឹក្សាអង់គ្លេស | កំណត់ហេតុយោង | កាលបរិច្ឆេទអនុម័តដោយក្រុមប្រឹក្សាភិបាលនៅអៀរឡង់ | កំណត់ហេតុយោង |
|---|---|---|---|---|---|---|---|
| | វិសោធនកម្មគោលនយោបាយ | ក្រុមប្រឹក្សាភិបាល 21 សីហា 2018 | | 11តុលា 2018 | កំណត់ហេតុ 11/10/18 | N/A | N/A |
| | បច្ចុប្បន្នភាពគោលនយោបាយ | ក្រុមប្រឹក្សាភិបាល 12 វិច្ឆិកា 2019 | | | | N/A | N/A |
| CVPPP/06/2020/1.0 | បច្ចុប្បន្នភាពគោលនយោបាយ | ក្រុមប្រឹក្សាភិបាល 29/06/2020 | របៀបវារៈទី8 | 21.7.20 | របៀបវារៈទី 5 | | |
| CVPPP/09/2020/1.0 | បច្ចុប្បន្នភាពគោលនយោបាយ | ក្រុមប្រឹក្សាភិបាល 16/09/2020 | របៀបវារៈទី8 | | | | |

# ឧបសម្ព័ន្ធ កៈ ក្រមសីលធម៌ក្នុងពេលការធ្វើការជាមួយកុមារ និងជនងាយរងគ្រោះ

អង្គការទស្សនៈឥតព្រំដែនបង្ហាញថា ការការពារកុមារនិង ជនងាយរងគ្រោះគឺជាការទទួលខុសត្រូវរបស់បុគ្គលិកគ្រប់គ្នា។ ដើម្បីគ្រប់គ្រងហានិភ័យនេះអោយមានប្រសិទ្ធិភាព ដែលអាចកើតឡើងចំពោះកុមារ អង្គការទស្សនៈឥតព្រំដែន តម្រូវអោយមានការសហការ និងគាំទ្រពីគ្រប់បុគ្គលិករបស់អង្គការទស្សនៈឥតព្រំដែនទាំងអស់។ អង្គការ ទស្សនៈឥតព្រំដែន ក៏លើកទឹកចិត្តអោយមានការអប់រំផ្សព្វផ្សាយស្តីអំពីបញ្ហាកុមារ និងជនងាយរងគ្រោះ នៅក្នុងសហគមន៍ក្នុងចំណោមអង្គការដៃគូរទាំងអស់ក្នុងប្រទេសកម្ពុជា ប្រទេសអូស្ត្រាលី និងប្រទេសអង់គ្លេសផងដែរ។

ជាតម្រូវការដែលបុគ្គលិកអង្គការទស្សនៈឥតព្រំដែនត្រូវតែបង្ហាញរាល់ការចោទប្រកាន់ភ្លាមៗ ផ្តន្ទាទោស និងលទ្ធផលផ្សេងទៀតនៃបទល្មើសដែលទាក់ទងនឹង ការកេងប្រវ័ញ្ច ការរំលោភបំពានលើកុមារ ដោយរាប់បញ្ចូលទាំង ច្បាប់ប្រពៃណីដែលកើតឡើងមុនពេល រឺកំឡុងពេលដែលពួកគេមានទំនាក់ទំនងជាមួយអង្គការទស្សនៈឥតព្រំដែន។

អង្គការទស្សនៈឥតព្រំដែន ព្យាយាម គ្រប់កន្លែងទាំងអស់ដែលអាចធ្វើបានក្នុងការកាត់បន្ថយ គ្រោះថ្នាក់ដែលបណ្តាលមកពីឥរិយាបទមិនសមរម្យរបស់បុគ្គលិកផ្ទាល់។ យោងតាមហេតុផលខាងលើ អង្គការទស្សនៈឥតព្រំដែន រក្សាសិទ្ធក្នុងការបញ្ឈប់រឺក៏ដកបុគ្គលិក នៅពេលដែលដឹងថាពួកគេ ធ្វើអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាព រឺសុខមាលភាពរបស់កុមារ និងជនងាយរងគ្រោះ។ បើកំណត់ឃើញថាហេតុផលសមរម្យ អង្គការទស្សនៈឥតព្រំដែន អាច ផ្អាកការងារបុគ្គលិក រឺបញ្ជូនពួកគេទៅកាន់តួនាទីផ្សេង ក្នុងកំឡុងពេលនៃការស៊ើបអង្កេត។

## ទំនួលខុសត្រូវរបស់យើង

**<u>បុគ្គលិកអង្គការទស្សនៈឥតព្រំដែន និងដៃគូនឹងៈ</u>**

- ✓ ប្រព្រឹត្តដោយស្មើភាពគ្នា និងគោរព ទោះបីមានភាពផ្សេងគ្នាដូចជា ជាតិសាសន៍ សាសនា អាយុ សមត្ថភាព ភេទ ចំណេះដឹងផ្លូវភេទ ការប្រណាំងប្រជែង ពណ៌សម្បុរ ភាសា និន្នាការនយោបាយ គំនិតផ្សេងគ្នា សញ្ជាតិ សង្គម ទ្រព្យសម្បត្តិ ពិការភាព ជាតិកំណើត ស្ថានភាពសេដ្ឋកិច្ច ។
- ✓ ប្រព្រឹត្តអោយស្របទៅតាមបុគ្គលិកលក្ខណៈ និងតួនាទី និងធ្វើខ្លួនអោយក្លាយទៅជាគំរូសំរាប់កុមារ និងសហគមន៍ និងក្នុងនាមជាអ្នកតំណាងអោយ អង្គការទស្សនៈឥតព្រំដែន។
- ✓ លើកឡើង និងរាយការណ៍ភ្លាមៗពីកង្វល់ ដែលពាក់ព័ន្ធនឹង សុខសុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ទៅកាន់ មន្ត្រីការពារកុមារនិងបរិយាប័នរបស់អង្គការទស្សនៈឥតព្រំដែន រឺក៏ជនបង្គោលទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ, អ្នកគ្រប់គ្រងផ្នែកត្រួតពិនិត្យនិងតាមដាន, អ្នកគ្រប់គ្រងប្រចាំប្រទេស, នាយកប្រតិបត្តិអង្គការ ដោយស្របទៅតាមនីតិវិធី នៃការរាយការណ៍ដែលមានចែងក្នុងក្រមសីលធម៌ និងនីតិវិធីនៃការរាយការណ៍របស់អង្គការទស្សនៈឥតព្រំដែន។
- ✓ ត្រូវមានអ្នកផ្សេងមើលឃើញនៅពេលធ្វើការជាមួយកុមារ និងជនងាយរងគ្រោះផ្សេងទៀត។
- ✓ ជៀសវាងការនៅតែពីរនាក់ជាមួយនឹងកុមារ និងជនងាយរងគ្រោះផ្សេងទៀត ធានាថា មនុស្សធំផ្សេងទៀតមាន វត្តមាននៅពេលធ្វើការជាមួយកុមារ។
- ✓ អនុវត្តស្របតាមច្បាប់ផ្សេងៗដែលមានការពាក់ព័ន្ធនឹង អង់គ្លេស អូស្ត្រាលី ច្បាប់ក្នុងស្រុក រាប់បញ្ចូលទាំង ច្បាប់ស្តីពីពលកម្មកុមារ។

**<u>បុគ្គលិកអង្គការទស្សនៈឥតព្រំដែន និងដៃគូនឹងមិនៈ</u>**

- ប្រព្រឹត្តឥរិយាបទ ដែលមានបំណងធ្វើអោយអាម៉ាស់ បង្អាប់ មើលងាយ បកអាក្រាតនៅក្នុងចំណោមមនុស្ស
- ប្រើប្រាស់ភាសា ស្នើផ្តល់យោបល់ក្នុងឥរិយាបទមិនសមរម្យ រើសអើង មើលងាយ បៀតបៀន ទាក់ទាញផ្លូវភេទ បន្ទាបតម្លៃ រឺ វប្បធម៌ដែលមិនសមរម្យ និងឈានទៅដល់ការរំលោភបំពាន។
- ផ្តល់អោយកុមារនូវស្រា គ្រឿងញៀន ដែលវាជាឥរិយាបទមិនសមរម្យ។
- បង្ហាញអោយឃើញនូវការប្រព្រឹត្តដែលមិនស្មើភាពគ្នា ទៅលើកុមារ និងជនងាយរងគ្រោះហើយ ដោយរាប់បញ្ចូលទាំងការផ្តល់អំណោយដល់កុមារ។
- បំរើសកម្មភាពឯកជនរបស់កុមារ នៅពេលដែលពួកគេអាចធ្វើខ្លួនឯងបាន ដូចជា ផ្លាស់ប្តូរសំលៀកបំពាក់ ឬជំនួយការផ្សេងៗក្នុងបង្គន់។
- យកកុមារ ឬជនងាយរងគ្រោះទៅកន្លែងស្នាក់នៅរបស់ខ្លួន លើកលែងតែកុមារស្ថិតក្នុងស្ថានភាពរងគ្រោះអាសន្នដោយរបួស និងមានគ្រោះថ្នាក់ធ្ងន់ធ្ងរលើរូបរាងកាយ។
- គេងលើគ្រែ រឺបន្ទប់រួមគ្នាជាមួយកុមារឬជនងាយរងគ្រោះ លើកលែងតែចាំបាច់បំផុត ហើយក្នុងករណីនេះត្រូវតែ មានការអនុញ្ញាតពីប្រធានក្រុម ហើយមនុស្សពេញវ័យផ្សេងទៀតត្រូវតែមានវត្តមានជាចាំបាច់។
- ដាក់វិន័យដោយប្រើប្រាស់ទណ្ឌកម្មលើកុមារនិងជនងាយរងគ្រោះ។
- បង្កឳកាសឱ្យកុមារឬ ជនងាយរងគ្រោះចូលរួមសកម្មភាពផ្លូវភេទ រាប់បញ្ចូលទាំងការចំណាយលុយលើសកម្មភាពផ្លូវភេទ។
- ប្រព្រឹត្តគ្រប់សកម្មភាពដែលអាចជា សកម្មភាពរំលោភបំពាន និងដាក់កុមារ ឬជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះ និងគ្រោះថ្នាក់។
- ធ្វើសកម្មភាពដែលអាចចាត់ទុកថាជាការរំលោភបំពាន ឬក៏ដាក់កុមារ រឺជនងាយរងគ្រោះស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់។
- ប្រព្រឹត្តលើរូបរាងកាយ ដែលមានបុគ្គលិកលក្ខណៈមិនសមរម្យ ដែលអាចឈានទៅដល់សកម្មភាពផ្លូវភេទ ចំពោះកុមារ និង ជនងាយរងគ្រោះ។
- មានអាកប្បកិរិយាផ្នែករាងកាយដែលមិនសមរម្យ ឬបង្កអោយមានសកម្មភាពផ្លូវភេទជាមួយកុមារ និងជនងាយរង គ្រោះ។
- ការព្រងើយកន្តើយ ឬចូលរួម ក្នុងទង្វើចំពោះកុមារ ដែលជាទង្វើខុសច្បាប់ អសុវត្ថិភាព ឬរំលោភបំពានចំពោះកុមារ។
- កត់ត្រា រឺផ្សព្វផ្សាយព័ត៌មានលំអិត ដូចជាឈ្មោះ រឺអស័យដ្ឋានរបស់កុមារ ឬជនងាយរងគ្រោះជាមួយរូបថត
- អោប ថើប អង្អែល កុមារ និងជនងាយរងគ្រោះ ក្នុងស្ថានភាពមិនសមរម្យ មិនចាំបាច់ ឬ ប្រើប្រាស់វប្បធម៌ដែលមិនសមរម្យ។ ការប៉ះពាល់អាចធ្វើបានតែក្នុងការឆ្លើយតបនឹងតម្រូវការផ្ទាល់ខ្លួនកុមារ ហើយក៏ត្រូវមានការអនុញ្ញាតពីសាម៉ីខ្លួនផងដែរ (ដូចជាក្នុងស្ថានភាពបន្ទាន់)។ ជៀសវាង ដើមទ្រូង គូថ ក្រលៀន ហើយដោយចំហរ និងគ្មានភាពលាក់លៀម។

- ប្រើ កុំព្យូទ័រ ឬទូរស័ព្ទ វីដេអូ ឬ កាមេរ៉ា ដែលមិនសមរម្យ ឬ ប្រើវាទាញមើលរូបភាព ឬវីដេអូអំពីកុមារដែលកំពុងត្រូវបានគេរំលោភឬកេងប្រវ័ញ្ចផ្លូវភេទ ទោះក្នុងមធ្យោបាយណាក៏ដោយ។
- ជួលកុមារ រឺជនងាយរងគ្រោះ អោយធ្វើពលកម្មដោយមិនស្របតាម អាយុនិងប៉ះពាល់ដល់ការអភិវឌ្ឍ ប៉ះពាល់ម៉ោងសិក្សា សកម្មភាពកំសាន្តផ្សេងៗ ឬដាក់គាត់ក្នុងកន្លែងដែលងាយគ្រោះថ្នាក់ឬរបួស។

<u>នៅពេលមានការថតរូប ឬវីដេអូ អំពីកុមារ និងជនងាយរងគ្រោះ ឬប្រើប្រាស់រូបភាពក្នុងបរិបទការងារ អង្គការទស្សនៈឥតព្រំដែននឹងធានាថា៖</u>

- ប្រពៃណីឬការរឹតត្បិតក្នុងស្រុកចំពោះការផលិតរូបថតបុគ្គល ត្រូវបានអនុលោម មុនពេលថតរូបឬវីដេអូ។
- សេចក្តីយល់ព្រមផ្ទាល់មាត់ និងឯកសារយល់ព្រម(ជាលាយលក្ខណ៍អក្សរ)ពីឪពុកម្តាយឬអាណាព្យាបាលកុមារ មុនពេលថតរូប ឬវីដេអូ និងពន្យល់ពីគោលបំណងនៃការប្រើប្រាស់រូបភាព និងវីដេអូនេះ។ ដំណើរការនេះត្រូវធ្វើឡើងជាភាសាខ្មែរ។
- រាល់ការផ្សព្វផ្សាយត្រូវបង្ហាញអំពីភាពថ្លៃថ្នូរ និងគោរព មិនមែនស្ថានភាព ឬឥរិយាបទងាយរងគ្រោះ គោកយ៉ាករបស់កុមារឡើយ។ កុមារត្រូវមានសម្លៀកបំពាក់សមរម្យ និងមិនបង្ហាញពីភាពទាក់ទាញផ្លូវភេទឡើយ។
- រូបភាពគឺបង្ហាញពីភាពស្មោះត្រង់ និងបង្ហាញស្ថានភាព និងបរិបទជាក់ស្តែង
- ឈ្មោះឯកសារ យោងទិន្នន័យ និងសេចក្តីបរិយាយឯកសារទាំងឡាយមិនបានបង្ហាញអោយដឹងអំពីព័ត៌មានសម្គាល់អត្តសញ្ញាណរបស់កុមារ ឬមនុស្សងាយរងគ្រោះ នៅពេលដែលផ្ញើរូបភាពតាមសារអេឡិចត្រូនិច ឬបង្ហាញរូបនេះជាសារធារណៈក្នុងទំរង់ណាក៏ដោយ។ នេះរួមបញ្ចូលឈ្មោះពេញ ឈ្មោះសាលា ព័ត៌មានលម្អិតពីទីតាំងជាក់លាក់ ព្រមទាំងព័ត៌មានដទៃទៀតដែលអាចបង្កឱ្យភាគីទីពឈានទៅកំណត់អត្តសញ្ញាណ និងចូលដល់ទីតាំងជននោះតាមរយៈការផ្សព្វផ្សាយរបស់អង្គការទស្សនៈឥតព្រំដែន។ ចាត់តាំងជ្រើសរើសបុគ្គលិកម្នាក់របស់អង្គការ ទស្សនៈឥតព្រំដែន ឱ្យអាចចូលត្រួតពិនិត្យបណ្ណាល័យរូបថត និងឯកសារអនុញ្ញាតឱ្យថតរូប ដើម្បីប្រាកដថា មានឯកសារបញ្ជាក់ការអនុញ្ញាតត្រឹមត្រូវមុនធ្វើការផ្សព្វផ្សាយណាមួយ។

<u>ទំនួលខុសត្រូវក្នុងនាមជាសាក្សីនៅពេលសកមត្ថភាពមិនសមរម្យកើតឡើង</u>

បុគ្គលិកអង្គការទស្សនៈឥតព្រំដែន និងធ្វើសាក្សី នៅពេលដែលនរណាម្នាក់ប្រព្រឹត្តសកម្មភាពប្រាសចាកពីគោលនយោបាយ ហើយចូលទៅក្នុងទំរង់នៃការរំលោភបំពាន ដូចបានលើកឡើងក្នុងផ្នែកទី ៥ (និយមន័យ) វាជាទំនួលខុសត្រូវ របស់បុគ្គលិកនោះដែលត្រូវរាយការណ៍ និងធ្វើសាក្សី ដល់មន្ត្រីការពារកុមារ ឬបើមិនសម អ្នកអាចរាយការណ៍ទៅកាន់ អ្នកគ្រប់គ្រងផ្នែកត្រួតពិនិត្យនិងតាមដាន អ្នកគ្រប់គ្រងប្រចាំប្រទេស ប្រធានអង្គការ ឬអ្នកណាផ្សេងទៀតដែលស្ថិតក្នុង ក្រុមអ្នកគ្រប់គ្រង **ទោះជាជនល្មើសពាក់ព័ន្ធ រឺមិនពាក់ព័ន្ធអង្គការទស្សនៈឥតព្រំដែនក៏ដោយ**។ ព័ត៌មានលំអិតពីរបៀបរាយការណ៍ និងអ្វីដែលត្រូវរាយការណ៍មានភ្ជាប់ នៅក្នុង ឧបសម្ព័ន្ធ (គ)។ អ្នករាយការណ៍អាចនឹងត្រូវបានស្នើសុំអោយមានការសហការក្នុងការស៊ើបអង្កេត។

## ឧបសម្ព័ន្ធ(ខ)៖ អ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ និងអ្នកចុះមើលគំរោងផ្សេងទៀត- ដំណើរការនៃការធានា

អង្គការទស្សនៈឥតព្រំដែន ទទួលស្គាល់តម្រូវការនៃការអនុវត្តសេចក្តីណែនាំជាក់លាក់ ដើម្បីគ្រប់គ្រងហានិភ័យ ដែលទាក់ទង នឹងការការពារកុមារ និងជនងាយរងគ្រោះ ពីអ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ និងភ្ញៀវទស្សនាគម្រោងផ្សេងទៀត។

សេចក្តីណែនាំរាប់បញ្ចូលទាំង៖

| ប្រភេទនៃភ្ញៀវ | បរិយាយពីការធ្វើទស្សនៈកិច្ច | គោលការណ៍កិច្ចបង្ការហានិន័យ |
|---|---|---|
| គ្រូដែលជាអ្នកស្ម័គ្រចិត្ត | រៀងរាល់ខែមករា អង្គការទស្សនៈឥតព្រំដែន បានអញ្ជើញគ្រូដែលមានសមត្ថភាព ពីអូស្ត្រាលី អង់គ្លេស អៀរឡង់ ដើម្បីចូលរួមជាមួយយើងក្នុងប្រទេសកម្ពុជា ពីរសប្តាហ៍ ដើម្បីចែករំលែកពីបទពិសោធន៍។ | ភ្ញៀវទាំងអស់ត្រូវបានរៀបចំជាមុនតាមរយៈការិយាល័យអង្គការទស្សនៈឥតព្រំដែន និងគ្រូស្ម័គ្រចិត្ត (ឱកាសខ្លះគឺពួកគេមកជាមួយនឹងគ្រួសារ) ត្រូវបានជ្រើសរើស តាមរយៈដំណើរការរបស់យើង រាប់បញ្ចូលទាំង (មិនកំណត់) ការត្រួតពិនិត្យលើសាក្សី លិខិតត្រួតពិនិត្យពីប៉ូលីស។ ក្នុងករណីសមាជិកគ្រួសារណាម្នាក់មិនមានលិខិតត្រួតពិនិត្យពីប៉ូលីសនោះទេ ពួកគេអាចបំពេញនិងចុះហត្ថលេខាលើទម្រង់លិខិតស្វ័យប្រកាសភាពស្អាតស្អំនិងគោរពគោលការណ៍ការពារកុមារនិងជនងាយរងគ្រោះ (ដោយសមស្រប)។ រាល់ភ្ញៀវដែលមកទស្សនៈកិច្ចទាំងអស់តម្រូវអោយ អាន និងចុះហត្ថលេខាលើ សេចក្តីប្រកាសផ្ទាល់ខ្លួន ដូចដែលបានកំណត់ក្នុងគោលនយោបាយកិច្ចបង្ការសុវត្ថិភាព គោលនយោបាយការពារកុមារ និងក្រមសីលធម៌។<br><br>គ្រូស្ម័គ្រចិត្ត និងត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពី ការការពារកុមារ និង កិច្ចបង្ការសុវត្ថិភាព ដោយសង្ខេប រាប់បញ្ចូលទាំងនីតិវិធី និងឥរិយាបថនៃកិច្ចការពារកុមារ។<br><br>គ្រូទាំងអស់ដែលធ្វើទស្សនៈកិច្ចនៅតាមសាលា គឺត្រូវតែអមដំណើរដោយបុគ្គលិករបស់អង្គការទស្សនៈឥតព្រំដែន តាមចំនួនដែលសមស្រប។<br><br>ការផ្លោះប្តូរ សារអេឡិចត្រូនិច រឺអាសយដ្ឋានផ្សេងៗ (រាប់បញ្ចូលទាំងវេទិការតាម អ៊ីនធឺណែត) មិនត្រូវបានអនុញ្ញាត ឡើយ។<br><br>ការពិចារណាផ្សេងទៀត៖<br>គ្រូត្រូវមានទំនួលខុសត្រូវចំពោះការចេញពីសកម្មភាពសាលានៅពេលដែលកម្មវិធីបញ្ចប់។ វាចាំបាច់ក្នុងការនិយាយថាភ្ញៀវមិន |

| | | |
|---|---|---|
| | | អាចអនុញ្ញាតអោយស្នាក់នៅផ្ទះ មណ្ឌល ឬសហគមន៍របស់កុមារ នៅពេលយប់នោះទេ។<br><br>ប្រសិនបើគ្រូស្ម័គ្រចិត្តធ្វើខុសអំពី គោលនយោបាយនេះ ពួកគេនឹងត្រូវបាននាំទៅព្រលានយន្តហោះហើយត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ ឬអាចឈានដល់រាយការណ៍ទៅអជ្ញាធរមានសមត្ថកិច្ចបើចាំបាច់។<br><br>ចំពោះស្ថានភាពបែបនេះ អង្គការទស្សនៈឥតព្រំដែន នឹងផ្តាច់ទំនាក់ទំនង ហើយមិនមានការពាក់ព័ន្ធអ្វីជាមួយបុគ្គលនោះនៅថ្ងៃមុខ។ |
| បុគ្គលិកគាំទ្រ និងអ្នកស្ម័គ្រចិត្ត | អង្គការទស្សនៈឥតព្រំដែនផ្តល់ឱកាសធ្វើការស្ម័គ្រចិត្តរយៈពេលខ្លីក្នុងការិយាល័យប្រទេសកម្ពុជារយៈពេលរហូតដល់៦ខែ និងពេលខ្លះអាចយូរជាងនេះសម្រាប់អ្នកជំនាញឯកទេសសមស្របតាមតម្រូវការរយៈរបស់អង្គការ។ | កិច្ចសន្យារបស់អ្នកស្ម័គ្រចិត្ត ត្រូវរៀបចំជាមុនតាមរយៈការិយាល័យរបស់អង្គការទស្សនៈឥតព្រំដែន ហើយអ្នកស្ម័គ្រចិត្តត្រូវបានជ្រើសតាមរយៈដំណើរការរបស់គោលនយោបាយធនធានមនុស្ស រាប់បញ្ចូលទាំង (មិនកំណត់)លិខិតត្រួតពិនិត្យរបស់ប៉ូលីសបញ្ជាក់ពីភាពសមស្របសម្រាប់ធ្វើការជាមួយកុមារ។ អ្នកស្ម័គ្រចិត្ត រំពឹងថានឹងបានអាន និងចុះហត្ថលេខាលើលិខិតស្វ័យប្រកាស ដើម្បីគោរពចំពោះការអនុវត្តន៍គោលនយោបាយ ទាំងអស់ដូចជា គោលនយោបាយកិច្ចបង្ការហានីភ័យ គោលនយោបាយកិច្ចការពារកុមារនិងជនរងគ្រោះ និងក្រមចរិយាធម៌របស់អង្គការ។<br><br>បុគ្គលម្នាក់ៗនឹងចូលរួមវគ្គបណ្តុះបណ្តាល ស្តីអំពីកិច្ចបង្ការហានីភ័យដែលជាផ្នែកមួយនៃការណែនាំអំពីអង្គការទស្សនៈឥតព្រំដែន មុនពេលចុះធ្វើទស្សនៈកិច្ចតាមសាលា ។<br><br>ការផ្តោះប្តូរ សារអេឡិចត្រូនិច រឺអស័យដ្ឋានផ្សេងៗ (រាប់បញ្ចូលទាំងវេទិការតាម អ៊ីនធឺណែត) មិនត្រូវបានអនុញ្ញាតឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ។<br><br>ការពិចារណាផ្សេងទៀត គឺដូចអ្វីដែលមានចែងសំរាប់ គ្រូស្ម័គ្រចិត្តខាងលើ។ |
| ម្ចាស់ជំនួយ | ទស្សនៈកិច្ចផ្ទាល់ជាបុគ្គលមកប្រទេសកម្ពុជា ដែលជា | ភ្ញៀវទស្សនៈកិច្ចទាំងអស់ត្រូវបានរៀបចំជាមុនតាមរយៈការិយាល័យអង្គការទស្សនៈឥតព្រំដែន។ |

| | | |
|---|---|---|
| | ម្ចាស់ជំនួយសំខាន់សំរាប់អង្គការទស្សនៈឥតព្រំដែន គឺជារឿយៗត្រូវបានអញ្ជើញសំរាប់ការទស្សនៈកិច្ចដើម្បីពិនិត្យលើស្ថានភាពការងាររបស់យើង។ | បុគ្គលម្នាក់ៗត្រូវបំពេញទម្រង់លិខិតស្វ័យប្រកាសភាពស្អាតស្អំ និងគោរពគោលការណ៍ការពារកុមារនិងជនងាយរងគ្រោះ ព្រមទាំងអាននិង ចុះហត្ថលេខា ដើម្បីបញ្ជាក់ពីការព្រមព្រៀងអនុវត្តដោយគោរព ចំពោះគោលនយោបាយទាំងនេះ ដោយរាប់បញ្ចូលទាំងគោលនយោបាយកិច្ចបង្ការសុវត្ថិភាព គោលនយោបាយកិច្ចការពារកុមារនិងជនរងគ្រោះ និងក្រមចរិយាធម៌របស់អង្គការ។<br><br>ម្ចាស់ជំនួយនឹងត្រូវអមដំណើរដោយបុគ្គលិកជាន់ខ្ពស់នៃអង្គការទស្សនៈឥតព្រំដែនកម្ពុជាគ្រប់គ្រងគ្រប់ពេលនៅសាលាឡើយ (មិនលើស ពី ២ ទៅ ៣ម៉ោង) ដូច្នេះមាន ការទាក់ទងជាមួយនឹងកុមារតិចតួចបំផុត។<br><br>ការផ្លោះប្តូរ សារអេឡិចត្រូនិច រឺអាសយដ្ឋានផ្សេងៗ (រាប់បញ្ចូលទាំងវេទិការតាម អ៊ីនធឺណែត) មិនត្រូវបានអនុញ្ញាតឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ។<br><br>ការពិចារណាផ្សេងទៀត គឺដូចទៅនឹងអ្វីដែលមានចែងសម្រាប់គ្រូស្ម័គ្រចិត្តខាងលើ។ |
| ក្រុមភ្ញៀវក្រុមហ៊ុនសាជីវកម្ម | ក្រុមហ៊ុនជាដៃគូសហការរយៈពេលវែង ត្រូវបានអញ្ជើញអោយចូលរួមជាមួយអង្គការទស្សនៈឥតព្រំដែន ប្រទេសកម្ពុជា លើសពី ២សប្តាហ៍ រៀងរាល់ឆ្នាំ ក្នុងការងារស្ម័គ្រចិត្ត ចែករំលែកបទពិសោធន៍ និងចូលរួមស្វែងយល់ពីភាពស្មុគស្មាញដែលយើងកំពុងតែជួបប្រទះនៅក្នុងការខំប្រឹងប្រែងរបស់យើង ក្នុងការប្រើប្រាស់ជំនួយរបស់ក្រុមហ៊ុនប្រកបដោយអត្ថន័យបំផុត។ | រាល់ការធ្វើទស្សនៈកិច្ចទាំងអស់ ត្រូវបានរៀបចំជាមុនតាមរយៈការិយាល័យរបស់យើង ហើយអ្នកចូលរួម និងត្រូវបានជ្រើសរើសដោយអង្គភាពក្រុមហ៊ុនដោយយកតែអ្នកដែលមានឥរិយាបទល្អ។<br><br>ភ្ញៀវចូលរួមតម្រូវអោយមានលិខិតបញ្ជាក់ពីប៉ូលីស ឬលិខិតបញ្ជាក់អំពីឥរិយាបទស្តីពីការធ្វើការជាមួយកុមារ។<br><br>អ្នករួមដំណើរ ត្រូវរំពឹងថាបានអាននិង ចុះហត្ថលេខាលើ គោលនយោបាយស្តីពីកិច្ចការពារកុមារ និងជនរងគ្រោះ លិខិតប្រកាសផ្ទាល់ខ្លួន និងអនុវត្តន៍ដោយគោរព ចំពោះគោលនយោបាយទាំងនេះ ដោយរាប់បញ្ចូលទាំងគោលនយោបាយកិច្ចបង្ការសុវត្ថិភាព គោលនយោបាយកិច្ចការពារកុមារនិងជនរងគ្រោះ និងក្រមចរិយាធម៌របស់អង្គការ។<br><br>អ្នកស្ម័គ្រចិត្ត និងម្ចាស់ជំនួយទាំងអស់ នឹងទទួលបានការតម្រង់ទិសដោយសង្ខេបស្តីពីកិច្ចបង្ការសុវត្ថិភាព រាប់បញ្ចូលទាំង កិច្ចការពារកុមារ និងសេចក្តីណែនាំស្តីពីឥរិយាបទ។ |

| | | |
|---|---|---|
| | | អ្នកចូលរួមទាំងអស់និងតម្រូវអោយមានអមដំណើរដោយបុគ្គលិកអង្គការទស្សនៈឥតព្រំដែន។<br><br>ការផ្លោះប្តូរ សារអេឡិចត្រូនិច រឺអាសយដ្ឋានផ្សេងៗ (រាប់បញ្ចូលទាំងវេទិកាតាម អ៊ីនធឺណែត) មិនត្រូវបានអនុញ្ញាតឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ។<br><br>ការពិចារណាផ្សេងទៀត គឺដូចទៅនឹងអ្វីដែលមានចែងសំរាប់ គ្រូស្ម័គ្រចិត្តខាងលើ។ |
| សមាជិកក្រុមប្រឹក្សាភិបាល | សមាជិកក្រុមប្រឹក្សាភិបាល អូស្ត្រាលី និងចក្រភពអង់គ្លេស និងអៀរឡង់ ដែលមានទំនាក់ទំនងជាមួយយើងដោយចីរភាពគិតមកទល់ពេលធ្វើដំណើរ។ | សមាជិក្រុមប្រឹក្សាភិបាល គឺមានលិខិតបញ្ជាក់ពីប៉ូលីសស្តីពីការធ្វើការងារជាមួយកុមារ។ កម្មវិធីទស្សនៈកិច្ចរបស់ពួកគាត់គឺត្រូវរៀបចំទុកជាមុនដោយការិយាល័យពួកយើង។ សមាជិកក្រុមគ្រួសារផ្សេងទៀតត្រូវបានចាត់ចែងឱ្យអនុវត្តដូចជាម្ចាស់ជំនួយដែរ។<br><br>ក្នុងករណីសមាជិករួមដំណើរណាម្នាក់មិនមានលិខិតបញ្ជាក់ខាងលើរួចរាល់ជាមុនទេ ពួកគាត់គឺត្រូវបានរំពឹងទុកថា និងបានអាននិងចុះហត្ថលេខាលើ លិខិតស្វ័យប្រកាសដើម្បីធានាថា គោលនយោបាយកិច្ចបង្ការសុវត្ថិភាព រាប់បញ្ចូលទាំង កិច្ចការពារកុមារ និងក្រមចរិយាធម៌អង្គការ។<br><br>ភ្ញៀវទស្សនៈកិច្ចនឹងត្រូវអមដំណើរដោយបុគ្គលិកជាន់ខ្ពស់នៃអង្គការទស្សនៈឥតព្រំដែនកម្ពុជាគ្រប់គ្រងគ្រប់ពេលនៅសាលាឡើយ (មិនលើស ពី ២ ទៅ ៣ម៉ោង) ដូច្នេះមាន ការទាក់ទងជាមួយនឹងកុមារតិចតួចបំផុត។ |
| បុគ្គលិកឆ្លងប្រទេស ដែលមានការិយាល័យនៅបរទេស | នេះគឺរាប់បញ្ចូលទាំង បុគ្គលិក និងអ្នកស្ម័គ្រចិត្ត របស់អង្គការទស្សនៈឥតព្រំដែន ពីប្រទេសអូស្ត្រាលី និងចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ ដែលមកទស្សនៈកិច្ច តំបន់ប្រត្តិបត្តិការនៅកម្ពុជា។ | រាល់ទស្សនៈកិច្ចទាំងអស់ ត្រូវបានរៀបចំជាមុនតាមរយៈការិយាល័យរបស់យើង។<br><br>ក្នុងករណីមិនទាន់រួចរាល់ជាមុនទេ ទម្រង់លិខិតស្វ័យប្រកាសភាពស្អាតស្អំ និងគោរពគោលការណ៍ការពារកុមារ និងជនងាយរងគ្រោះ ព្រមទាំងអាននិង ចុះហត្ថលេខា ដើម្បីបញ្ជាក់ពីការព្រមព្រៀងអនុវត្តដោយគោរព ចំពោះគោលនយោបាយទាំងនេះ ដោយរាប់បញ្ចូលទាំងគោលនយោបាយកិច្ចបង្ការសុវត្ថិភាព គោលនយោបាយកិច្ចការពារកុមារនិងជនរងគ្រោះ និងក្រមចរិយាធម៌អង្គការ។ |

| | | |
|---|---|---|
| | | សមាជិកក្រុមបុគ្គលិក និងគ្រប់គ្រងដោយសមាជិកក្រុមថ្នាក់ដឹកនាំ នៃអង្គការទស្សនៈឥតព្រំដែនកម្ពុជាគ្រប់ពេល សំរាប់ដំណើរទស្សនៈកិច្ចរយៈនៅសាលាដែលពេលខ្លី (មិនលើសពី ២ ទៅ៣ ម៉ោង) ដូចច្នេះនឹងមានទំនាក់ទំនងជាមួយនឹងកុមារ តិចបំផុត។<br><br>ការផ្តោះប្តូរ សារអេឡិចត្រូនិច រឺអាសយដ្ឋានផ្សេងៗ (រាប់បញ្ចូលទាំងវេទិកាតាម អ៊ីនធឺណែត) មិនត្រូវបានអនុញ្ញាតឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ។<br><br>ការពិចារណាផ្សេងទៀត គឺដូចទៅនឹងអ្វីដែលមានចែងសំរាប់ គ្រូស្ម័គ្រចិត្តខាងលើ។ |

# ឧបសម្ព័ន្ធ(គ)៖ នីតិវិធីនៃការរាយការណ៍ពីករណីរំលោភបំពានលើកុមារ ការគាំទ្រ និងការឆ្លើយតប

អង្គការទស្សនៈឥតព្រំដែន ទទួលយកនូវក្តីព្រួយបារម្ភទាំងអស់និង ធ្វើការរាយការណ៍យ៉ាងហ្មត់ចត់នៅពេលមានការរំលោភបំពានលើកុមារ ដោយធ្វើការស៊ើបអង្កេត និងចាត់សកម្មភាពឆ្លើយតប។ មន្ត្រីការពារកុមារ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការងារទាំងអស់នេះ៖

### តើអ្នកណាដែលគួរត្រូវបានគេរាយការណ៍?

បុគ្គលិកអង្គការទស្សនៈឥតព្រំដែនទាំងអស់កំណត់ដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាល
- បុគ្គលិក និងអ្នកស្ម័គ្រចិត្តក្នុងសុពលភាព
- អ្នកប្រឹក្សាខាងក្រៅ ឬអ្នកជាប់កិច្ចសន្យា (មានប្រាក់ឈ្នួល ឬស្ម័គ្រចិត្ត)
- បុគ្គលិកកិច្ចសន្យា ឬបុគ្គលិកអង្គភាព និងសេវាផ្សេងៗដែលមានជាប់កិច្ចសន្យា
- អ្នកចូលរួមក្រុមការងារគម្រោង

អ្នកផ្សេងទៀតដែលធ្វើការអោយ ឬតំណាងអង្គការទស្សនៈឥតព្រំដែន

ទាំងសមីអង្គការផ្ទាល់ និងភាគីទីបី ដែលអាចមកពិនិត្យមើលការអនុវត្តសកម្មភាពរបស់អង្គការទស្សនៈឥតព្រំដែន តាមរយៈទំនាក់ទំនងជាមួយអង្គការទស្សនៈឥតព្រំដែន។

### តើគួររាយការណ៍អំពីអ្វី?

- ការបង្ហាញ ឬការចោទប្រកាន់អំពី ឬការសង្ស័យពីការរំលោភបំពានដែលត្រូវបានធ្វើឡើងដោយនរណាម្នាក់នៅក្នុងឬពាក់ព័ន្ធជាមួយអង្គការទស្សនៈឥតព្រំដែន រួមទាំងអ្នកទទួលផលនិងភាគីទីបី។
- ឥរិយាបថណាមួយដែលធ្វើឡើងដោយអ្នកស្ម័គ្រចិត្តឬភ្ញៀវរបស់អង្គការទស្សនៈឥតព្រំដែន ដែលបំពានគោលនយោបាយបង្ការហានីភ័យ និងកិច្ចការពារកុមារនិងជនងាយរងគ្រោះ។
- ការប្រើប្រាស់មិនត្រឹមត្រូវនូវរូបថត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតរបស់អង្គការ។
- បុគ្គលិក អ្នកស្ម័គ្រចិត្តនិងភ្ញៀវដែលមានអាកប្បកិរិយាគួរអោយសង្ស័យទាក់ទងនឹងការជួញដូរកុមារ ការកេងប្រវ័ញ្ច ការរំលោភបំពាននិងសកម្មភាពស្រដៀងគ្នា។
- ការសង្ស័យណាមួយនៃការរំលោភបំពាន, ការមិនយកចិត្តទុកដាក់ឬការកេងប្រវ័ញ្ចនៃកុមារឬអ្នកទទួលផលដែលជាជនងាយរងគ្រោះដែលអាចជាលទ្ធផលនៃសកម្មភាពរបស់នរណាម្នាក់ពីខាងក្រៅអង្គការទស្សនៈឥតព្រំដែន។

### តើត្រូវរាយការណ៍ទៅនរណា?

រាល់បាតុភាពឬករណីគួរបារម្ភអំពីការរំលោភលើកុមារឬជនងាយរងគ្រោះ វិធានបង្ការហានីភ័យ ការកេងប្រវ័ញ្ចផ្លូវភេទ រំលោភផ្លូវភេទ បៀតបៀនកេរខ្មាស ចាំបាច់ត្រូវរាយការណ៍ឱ្យបានលឿនបំផុត។ នៅគ្រប់ប្រទេសទាំងអស់ អ្នកដែលគួរទទួលបានរបាយការណ៍មុនគេគឺជនបង្គោលបង្ការហានីភ័យ ប៉ុន្តែក្នុងលក្ខខណ្ឌដែលមិនសក្តិសមរាយការណ៍ទៅជនបង្គោលនេះទេ (ឧទាហរណ៍៖ ករណីគាត់ជាប់សង្ស័យក្នុងបទចោទនោះ) មានមនុស្សផ្សេងទៀតដែលអ្នកអាចរាយការណ៍ជូនបានដូចជា៖

- នៅប្រទេសកម្ពុជា៖ ជនបង្គោលបង្ការហានីភ័យ (និងជាមន្រ្តីការពារកុមារ)៖ លោកស្រី តាន់ គិមឡែន
  ក្នុងលក្ខខណ្ឌដែលមិនសក្តិសមរាយការណ៍ទៅជនបង្គោលនេះទេ សូមរាយការណ៍ទៅអ្នកខាងក្រោម៖
    - អ្នកគ្រប់គ្រងទូទៅ ធនធានមនុស្ស និងហិរញ្ញវត្ថុ៖ Derek Culligan
    - ប្រចាំប្រទេស៖ ភឹង ពៅ
    - នាយកប្រតិបត្តិ៖ Edward Shuttleworth
- នៅប្រទេសអូស្ត្រាលី៖
  ជនបង្គោលបង្ការហានីភ័យ៖ លោកស្រី Priscilla Chang
  ក្នុងលក្ខខណ្ឌដែលមិនសក្តិសមរាយការណ៍ទៅជនបង្គោលនេះទេ សូមរាយការណ៍ទៅអ្នកខាងក្រោម៖
    - អ្នកគ្រប់គ្រងទូទៅ អូស្ត្រាលី៖ Andy Wade
    - នាយកប្រតិបត្តិ៖ Edward Shuttleworth
- នៅចក្រភពអង់គ្លេស៖
  ជនបង្គោលបង្ការហានីភ័យ៖ លោកស្រី Jayne Crow
  ក្នុងលក្ខខណ្ឌដែលមិនសក្តិសមរាយការណ៍ទៅជនបង្គោលនេះទេ សូមរាយការណ៍ទៅអ្នកខាងក្រោម៖
    - ប្រធានប្រចាំប្រទេស ចក្រភពអង់គ្លេស៖ Sarah Reynolds
    - នាយកប្រតិបត្តិ៖ Edward Shuttleworth

អង្គការទស្សនៈឥតព្រំដែន មានកាតព្វកិច្ចបន្ថែមដែលត្រូវរាយការណ៍ករណីឧប្បត្តិហេតុជូនម្ចាស់ជំនួយដូចខាងក្រោម៖

<u>ប្រទេសអូស្ត្រាលី</u>

វាជាកាតព្វកិច្ចដ៏ចាំបាច់ដែលអង្គការទស្សនៈឥតព្រំដែន (ក្នុងនាមជាដៃគូទទួលជំនួយពីDFAT) ត្រូវរាយការណ៍ភ្លាមៗនូវរាល់ករណីសង្ស័យ ឬចោទប្រកាន់ស្តីពីការកេងប្រវ័ញ្ច ការរំលោភកុមារ ឬការមិនអនុលោមគោលនយោបាយដោយបុគ្គលណាម្នាក់ក្នុងវិសាលភាពគោលនយោបាយការពារកុមាររបស់DFAT ទាក់ទងជាមួយករណីកិច្ចឬភារកិច្ចផ្លូវការ។ ការរាយការណ៍ទាំងអស់ត្រូវធ្វើទៅកាន់ childwelfare@dfat.gov.au.

របាយការណ៍ត្រូវភ្ជាប់មកជាមួយនូវទម្រង់ជូនដំណឹងអំពីការការពារកុមារ (Child Protection Notification Form) ដែលអាចរកបាននៅ www.dfat.gov.au/childprotection

បើសិនមានបន្ទិលថាតើករណីជាក់លាក់ណាមួយត្រូវតែរាយការណ៍ឬអត់ អង្គការទស្សនៈឥតព្រំដែនត្រូវសុំការពិគ្រោះយោបល់ជាសម្ងាត់ពីផ្នែកអនុលោមការពារកុមាររបស់DFAT នៅchildprotection@DFAT.gov.au ឬ +61 2 6178 5100.

<u>ចក្រភពអង់គ្លេស</u>

កង្វល់ទាក់ទងការបំពានគោលនយោបាយបង្ការហានីភ័យ គួររាយការណ៍ភ្លាមៗទៅកាន់ប្រអប់សំបុត្ររាយការណ៍ពីករណីគួរបារម្ភរបស់DFID តាមរយៈ reportingconcerns@dfid.gsx.gov.uk ឬតាមលេខHot lineសម្រាប់រាយការណ៍សម្ងាត់ +44 (0)1355 843 747 ។

## នីតិវិធីរបស់អង្គការក្នុងការរាយការណ៍

ពេលករណីការពារកុមារ ឬការបំពានគោលនយោបាយត្រូវបានរាយការណ៍ ភ្លាមនោះវិធានការខាងក្រោមនឹងត្រូវអនុវត្តៈ

1. មន្ត្រីការពារកុមារនឹងបំពេញទម្រង់របាយការណ៍ករណីគួរបារម្ភជាមួយព័ត៌មានដែលមានបច្ចុប្បន្ន(អាចរកបាននៅក្នុង SBB New Drive/Administration/Published Documents/Supporting Documentation)
2. មន្ត្រីការពារកុមារ នឹងរាយការណ៍ករណីនោះទៅកាន់ប្រធានអនុលោម ឬនិងនាយកប្រតិបត្តិ
3. ប្រធានអនុលោមនឹងបំពេញទម្រង់ Child Incident Notification form (ផ្តល់ដោយ DfAT និងរក្សាទុកនៅ here in SBB New Drive/Administration/Published Documents/Supporting Documentation)
4. ប្រធានអនុលោមនឹងផ្ញើ Child Incident Notification form ទីកាន់ childwelfare@dfat.gov.au ក្នុងកំឡុង២៤ម៉ោងក្រោយទទួលបានរបាយការណ៍។
5. ប្រធានអនុលោមនឹងជូនដំណឹងទៅ DFIDស្តីពីករណីចោទ ឬសង្ស័យ តាម reportingconcerns@dfid.gsi.gov.uk
6. មន្ត្រីការពារកុមារ នឹងបន្តការស៊ើបអង្កេតដើម្បីទទួលបានព័ត៌មានបន្ថែម(បើចាំបាច់) ហើយចាត់វិធានការសមស្របនៅកម្រិតមូលដ្ឋាន (ដូចជារាយការណ៍ទៅនាយកសាលា ការិយាល័យអប់រំស្រុក ភ្នាក់ងារជាតិ ឬនគរបាល) តាមការយល់ព្រមពីក្រុមអ្នកដឹកនាំ ឬពីនាយកប្រតិបត្តិ។
7. មន្ត្រីការពារកុមារនឹងបន្ថែមព័ត៌មានពិស្តារនៃករណីទៅក្នុងបញ្ជីការពារកុមារ។

- ឯកសារនឹងត្រូវរក្សាទុកក្នុងទីតាំងដែលមានសុវត្ថិភាពនៅក្នុងការិយាល័យអង្គការទស្សនៈឥតព្រំដែន(ប្រទេសកម្ពុជា អូស្ត្រាលី ឬចក្រភពអង់គ្លេសតាមការសមស្រប) សម្រាប់រយៈពេលអប្បបរមា ៧ ឆ្នាំ។

### ការរក្សាការសម្ងាត់

បុគ្គលិកទាំងអស់ត្រូវធានាថា ករណីទាំងអស់ត្រូវបានដោះស្រាយ តាមគោលការណ៍សម្ងាត់ សុវត្ថិភាព មិនលំអៀង ម៉ត់ចត់ ទៀងទាត់ និង សុក្រឹត្យ។

រាល់ពាក្យបណ្តឹង និងការរាយការណ៍ និងឈ្មោះអ្នកដែលពាក់ព័ន្ធ និងត្រូវរក្សាការសំងាត់បំផុត។ ព័ត៌មានលំអិត អាចប្រាប់តែអ្នកដែលចាំបាច់ត្រូវដឹងប៉ុណ្ណោះ ឬប្រសិនបើជាការតម្រូវរបស់ច្បាប់ក្នុងស្រុក អូស្ត្រាលី និងអង់គ្លេស ឬក៏ពេលមានការស្នើជាផ្លូវការពីប៉ូលីស ឬអាជ្ញាធរដែលមានតួនាទីការពារកុមារ។

## ឧបសម្ព័ន្ធ «យ»៖ស្តង់ដាអប្បបរមាទាំង៩របស់DFATស្តីពីការការពារកុមារ (DFAT's 9 Minimum Child Protection Standards[1])

| តម្រូវការ | ស្តង់ដាអប្បបរមា | ស្តង់ដាអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| ត្រូវមាននៅនឹងកន្លែងនូវគោលនយោបាយការពារកុមារ និងនីតិវិធីរាយការណ៍ | 1. ចំពោះស្ថាប័នដៃគូ<br><br>- អង្គការយើងមានគោលនយោបាយកិច្ចការពារកុមារដែលត្រូវអនុវត្តចំពោះបុគ្គលិកគ្រប់រូប បុគ្គលិករបស់ស្ថាប័នដៃគូ និងអ្នកជាប់កុងត្រាជាមួយ ដើម្បីចូលរួមចំណែកណាមួយនៃសកម្មភាព DFAT។<br><br>-ដៃគូជាស្ថប័នគ្រប់គ្រងត្រូវតែធានាថាអង្គភាពខាងក្រោមដៃនឱវាទ ឬរូបវន្តបុគ្គលចុះកុងត្រា គោរពតាមស្តង់ដាអប្បបរមាពាក់ព័ន្ធនៃគោលនយោបាយការពារកុមារ ។ | ចំពោះស្ថាប័នដៃគូ<br><br>- មានគោលនយោបាយកិច្ចការពារកុមារជាក់ស្តែង<br>- បុគ្គលិកគួរយល់ដឹងពីគោលនយោបាយកិច្ចការពារកុមាររបស់អង្គការ (ឧ.តាមរយៈទំនាក់ទំនងផ្ទៃក្នុង និងការបណ្តុះបណ្តាល)<br><br>-បានចងក្រងផែនការជាឯកសារ ដើម្បីធានាថាដៃគូដែលទទួលមូលនិធិពី DFAT កំពុងបំពេញតាមស្តង់ដាអប្បបរមា។<br><br>- ការវាយតម្លៃហានិភ័យស្តីពីការរៀបចំ និងធ្វើសកម្មភាព ដើម្បីជាមូលដ្ឋានចំណេះដឹងដល់ការអភិវឌ្ឍគោលនយោបាយ។ | - គោលនយោបាយកិច្ចការពារកុមារផ្តល់ការណែនាំយ៉ាងច្បាស់និងបង្ហាញពីរបៀបដែលអង្គការធ្វើការប្រតិបត្តិការរបស់ខ្លួន និងធានាថាកុមារត្រូវបានការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារកើតឡើងក្នុងសកម្មភាពគម្រោងដែលគាំទ្រថវិកាដោយមូលនិធិ DFAT។ | -អង្គការមួយមិនដឹងពីហានិភ័យចំពោះកុមារនៅក្នុងដំណើរការរៀបចំ និងសកម្មភាពដែលពួកគេគ្រប់គ្រងនិង/ឬអនុវត្ត។<br><br>-ការអោយអ្នកចុះកុងត្រា ចុះហត្ថលេខាលើក្រមសីលធម៌តែមួយមុខមិនគ្រប់គ្រាន់ក្នុងដោះស្រាយបញ្ហាការពារកុមារឡើយ។ |

[1] Extracted from DFAT Child Protection Policy, Jan 2018

| តម្រូវការ | ស្តង់ដាអប្បបរមា | ស្តង់ដាអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | **ចំពោះបុគ្គល**<br><br>អ្នកចុះកុងត្រាជាបុគ្គលមិនតម្រូវឱ្យមានគោលនយោបាយការពារកុមារទេ។ ទោះយ៉ាងនេះក៏ដោយពួកគេនឹងត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើក្រមនៃប្រតិបត្តិដែលអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈការពារកុមាររបស់DFAT (DFAT's Child Protection Professional Behaviours) និងគោលការណ៍បន្ថែមបើចាំបាច់ ព្រមទាំងផ្តល់ភស្តុតាងស្តីពីការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការការពារកុមារ។ | **ចំពោះបុគ្គល**<br><br>-ចូលរួមវគ្គបណ្តុះបណ្តាលការពារកុមារ<br><br>-ចុះហត្ថលេខាលើក្រមសីលធម៌<br><br>-ការប្តេជ្ញាចិត្តក្នុងការការពារកុមារ<br><br>-មានរបាយការណ៍ត្រួតពិនិត្យកំណត់ត្រាព្រហ្មទណ្ឌ | | |
| | 2.<br><br>គោលនយោបាយការពារកុមាររបស់អង្គការរួមបញ្ចូលឯកសារស្តីពីនីតិវិធីរាយការណ៍ពីបណ្តឹងទាក់ទងការកេងប្រវ័ញ្ចនិងការរំលោភបំពានកុមារ បំពានក្រមប្រតិបត្តិ និង | - គោលការណ៍ណែនាំរបស់អង្គការសម្រាប់ការគ្រប់គ្រងកង្វល់ឬការចោទប្រកាន់អំពីការកេងប្រវ័ញ្ចនិងការរំលោភបំពានលើកុមារនិងការមិនគោរពតាមគោលនយោបាយ | គោលនយោបាយការពារកុមារមានប្រសិទ្ធភាពទាមទារឱ្យមានសេចក្តីណែនាំអំពីនីតិវិធីរាយការណ៍។ | - បុគ្គលិកមិនបានយល់ដឹងពីរបៀបរាយការណ៍ពីអាកប្បកិរិយាគួរបារម្ភមួយចំនួន។ |

| តម្រូវការ | ស្តង់ដារអប្បបរមា | ស្តង់ដារអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | ការមិនគោរពតាមគោលនយោបាយ រួមទាំងការដាក់ទោសទណ្ឌសម្រាប់ការរំលោភបំពាននានា។ | - ឯកសារភស្តុតាង ដែលបញ្ជាក់ថាបុគ្គលិកអាចលើកឡើង ការព្រួយបារម្ភអំពីសុវត្ថិភាព សុខុមាលភាព ឬអាកប្បកិរិយាដែលមិនអាចទទួលយកប្រព្រឹត្តដោយបុគ្គលិក។<br>- ឯកសារភស្តុតាងបញ្ជាក់ពីព័ត៌មានលំអិតរបស់អង្គភាពអំពីការដាក់ទោសទណ្ឌ បើមាន<br>- ឯកសារដែលបង្ហាញថាគោលនយោបាយនិងព័ត៌មានស្តីពីរបៀបរាយការណ៍មានជាសាធារណៈនិងសមាជិកសហគមន៍អាចទទួលបានព័ត៌មាននេះ។ | ឧបសគ្គធំបំផុតក្នុងការរាយការណ៍អំពីការកេងប្រវ័ញ្ចនិងរំលោភបំពានលើកុមារគឺដោយសារការមិនមានប្រព័ន្ធជាក់លាក់ដើម្បីរាយការណ៍ ឬដោយសារបុគ្គលិក ឬសហគមន៍មិនបានដឹងអំពីនីតិវិធីផ្លូវការសម្រាប់រាយការណ៍អំពីការបារម្ភឬការចោទប្រកាន់។<br><br>ប្រព័ន្ធរាយការណ៍ត្រូវតែគោរពសិទ្ធិទាំងភាគីជនរងគ្រោះនិងជនត្រូវចោទ។ | - មនុស្សក្នុងសហគមន៍មិនបានយល់ដឹងពីរបៀបរាយការណ៍ពីអាកប្បកិរិយាគួរបារម្ភមួយចំនួន។ |

| តម្រូវការ | ស្តង់ដាអប្បបរមា | ស្តង់ដាអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | 3.<br>អង្គការផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីការការពារកុមារដល់បុគ្គលិករួមទាំងដៃគូអនុវត្តបន្តផងដែរ ។ | - កំណត់ត្រាវត្តមានចូលរួមវគ្គបណ្ដុះបណ្ដាល<br>- របៀបវារៈបណ្ដុះបណ្ដាលនិងពេលវេលាសម្រាប់បណ្ដុះបណ្ដាល<br>- សម្ភារៈប្រើប្រាស់ក្នុងការបណ្ដុះបណ្ដាល | បុគ្គលិកត្រូវតែដឹងយ៉ាងពេញលេញពីទំនួលខុសត្រូវរបស់ពួកគេក្នុងការការពារកុមារនិងវិធីរាយការណ៍ពីការព្រួយបារម្ភឬការចោទប្រកាន់អំពីការកេងប្រវ័ញ្ចនិងការរំលោភបំពានលើកុមារ។ | - បុគ្គលិកមិនដឹងពីអាកប្បកិរិយាដែលគួរឱ្យមានការព្រួយបារម្ភ។<br>- បុគ្គលិកមិនបានដឹងអំពីវិធីអនុវត្តការការពារកុមារទៅក្នុងការងាររបស់ពួកគាត់។<br>- បុគ្គលិកមិនដឹងពីរបៀបរាយការណ៍អំពីអាកប្បកិរិយាដែលគួរអោយបារម្ភមួយ។ |
| | 4.<br>គោលនយោបាយការពារកុមាររបស់អង្គការរួមបញ្ចូលការប្ដេជ្ញាចិត្តក្នុងការរារាំងកុំអោយមនុស្សណាម្នាក់មិនឱ្យធ្វើការជាមួយកុមារបើឃើញថាជននោះអាចបង្កហានិភ័យដែលមិនអាចទទួលយកបានចំពោះកុមារ។ | មានយោងនៅក្នុងឯកសារពាក់ព័ន្ធដូចជាគោលនយោបាយផ្សេងៗ កិច្ចសន្យាការងារនិងគោលការណ៍ណែនាំធនធានមនុស្ស | អង្គការក្នុងនាមជានិយោជកត្រូវតែមានមូល ដ្ឋានច្បាស់លាស់ដើម្បីកំណត់ថាមនុស្សណាម្នាក់សមស្របបំផុតក្នុងការធ្វើការជាមួយកុមារដែរឬទេ។ | - កង្វះខាតនៃការដឹកនាំ និងអភិបាលកិច្ច និងវប្បធម៌ត្រឹមត្រូវអាចបន្ថយប្រសិទ្ធភាពនៃកិច្ចខិតខំអនុវត្តបរិស្ថានការពារកុមាររបស់បុគ្គលិក។ |
| | 5. | គោលនយោបាយនេះគឺស្ថិតក្រោមលក្ខខណ្ឌតម្រូវការត្រួតពិនិត្យជាទៀងទាត់តាមឆន្ទៈ | បរិបទតែងផ្លាស់ប្ដូរជាពិសេសនៅក្នុងវិស័យ | - មេរៀនបទពិសោធន៍ដែលបានរៀនពីឧប្បត្តិហេតុម |

| តម្រូវការ | ស្តង់ដារអប្បបរមា | ស្តង់ដារអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | គោលនយោបាយការពារកុមាររបស់អង្គការ គឺស្ថិតក្រោមលក្ខខណ្ឌតម្រូវការត្រួតពិនិត្យជាទៀងទាត់យ៉ាងហោចណាស់រៀងរាល់ ៥ ឆ្នាំឬលឿនជាងនេះប្រសិនបើចាំបាច់។ | ដោយគោលនយោបាយ ឬយ៉ាងហោចណាស់រៀងរាល់ ៥ ឆ្នាំ។ | អភិវឌ្ឍន៍។ ត្រូវតែមានការប្តេជ្ញាចិត្តក្នុងការពិនិត្យមើលឡើងវិញនិងធ្វើបច្ចុប្បន្នភាពគោលនយោបាយតាមការតម្រូវ។ | នៗ មិនត្រូវបានយកមកគិតដែលបង្កើនលទ្ធភាពដែលហានិភ័យទាំងនោះកើតឡើងជាថ្មីដដែលៗ។ |
| ការសិក្សាវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ | 6.<br><br>អង្គការធ្វើការសិក្សាវាយតម្លៃហានិភ័យដើម្បីកាត់បន្ថយហានិភ័យចំពោះកុមារណាដែលរងគ្រោះថ្នាក់ដោយសារប្រតិបត្តិការឬសកម្មភាពដែលផ្តល់មូលនិធិដោយ DFAT ។ ការវាយសិក្សាត្រូវតែកំណត់ហានិភ័យហើយរៀបចំឯកសារស្តីពីជំហាន ដើម្បីកាត់បន្ថយឬបំបាត់នូវហានិភ័យទាំងនេះ។ | - ផែនការហានិភ័យដែលកំណត់សកម្មភាព និងវិធានការណ៍ដើម្បីកាត់បន្ថយ ឬបំបាត់ហានិភ័យលើកុមារ។<br><br>- ចងក្រងឯកសារដែលបញ្ជាក់ថារង្វាយតម្លៃហានិភ័យត្រូវតែពិនិត្យនិងធ្វើបច្ចុប្បន្នភាពជាប្រចាំក្នុងកំឡុងពេលនៃសកម្មភាព។<br><br>- ភស្តុតាងនៃការសម្របខ្លួនទៅនឹងបរិបទក្នុងតំបន់ (នៅពេលចាំបាច់ត្រូវការវិធីសាស្រ្តផ្សេងក្នុងការគ្រប់គ្រងហានិភ័យ)។ | សកម្មភាពខ្លះមានហានិភ័យខ្ពស់ជាងសកម្មភាពផ្សេងទៀត។ នេះអាចបណ្តាលមកពីធម្មជាតិនៃសកម្មភាពឬទីតាំង។ ឧទាហរណ៍ការធ្វើការជាមួយកុមារមានពិការភាពឬក្នុងស្ថានភាពអាសន្នពាក់ព័ន្ធនឹងហានិភ័យខ្ពស់។ | - ហានិភ័យចំពោះកុមារមិនត្រូវបានគិតគូក្នុងអំឡុងពេលតាក់តែងផែនការសកម្មភាព និងអំឡុងពេលអនុវត្ត។ |

| តម្រូវការ | ស្តង់ដារអប្បបរមា | ស្តង់ដារអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| **មានអនុវត្តន៍ជាក់ស្តែងក្នុងដំណើរការជ្រើសរើស សម្រាំង និងជួលបុគ្គលិក។** | 7.<br>- កិច្ចសន្យាការងាររបស់អង្គការនេះ មានបទប្បញ្ញត្តិសម្រាប់ការព្យួរឬផ្ទេរភារកិច្ចផ្សេងទៀតរបស់និយោជិតណាដែលស្ថិតក្រោមការស៊ើបអង្កេតនិងបទប្បញ្ញត្តិក្នុងការបណ្តេញនិយោជិតបន្ទាប់ពីការស៊ើបអង្កេត។ | - កិច្ចសន្យាការងារសម្រាប់បុគ្គលិក ឬអ្នកប្រឹក្សាយោបល់មានចែងបទប្បញ្ញតិសមស្រប | ការជ្រើសរើស ការសម្រាំងច្បាស់លាស់និងការអនុវត្តការងារយ៉ាងរឹងមាំ ពង្រឹងការយល់ដឹងពីសារៈសំខាន់នៃគោលនយោបាយការពារកុមាររបស់អង្គការចំពោះបុគ្គលិក។ | - បុគ្គលដែលបង្ក ហានិភ័យមិនអាចទទួលយកបានចំពោះកុមារ មិនអាចដកចេញ (ព្យួរ ផ្ទេរឬ បញ្ចប់កិច្ចសន្យា) ដោយគ្មានការផ្តន្ទាទោសព្រហ្មទណ្ឌ។ |
| | 8.<br>**តួនាទីដែលមានការទំនាក់ទំនងផ្ទាល់ជាមួយកុមារ**<br>អង្គការនេះមានដំណើរការជ្រើសរើសសម្រាំងបុគ្គលិកយ៉ាងរឹងមាំសម្រាប់បុគ្គលិកទាំងអស់ដែលទាក់ទងជាមួយកុមារ។ | - រក្សាឯកសារត្រួតពិនិត្យកំណត់ត្រាទោសទណ្ឌសម្រាប់បុគ្គលិកដែលទាក់ទងជាមួយកុមារ<br>- រក្សាឯកសារសម្ភាសផ្ទាល់មាត់ជាមួយអ្នកធានា។ | ដំណើរការជ្រើសរើសបុគ្គលិកបែបសុវត្ថិភាពកុមារអាចជួយឱ្យអង្គភាពរកបានមនុស្សដែលសក្តិសមបំផុតសម្រាប់មុខតំណែងមានការផ្ទាល់ជាមួយកុមារ។ | អង្គភាពរបស់អ្នកអាចក្លាយជាគោលដៅរបស់មនុស្សពេញវ័យដែលមានបំណងធ្វើបាបកុមារ (ដោយសារតែការអនុវត្តវិធីជ្រើសរើស និងការត្រួតពិនិត្យបុគ្គលិក មានភាពធូររលុង) |

| តម្រូវការ | ស្តង់ដាអប្បបរមា | ស្តង់ដាអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | នីតិវិធីជ្រើសរើសបុគ្គលិករួមមាន៖<br>- ការត្រួតពិនិត្យប្រវត្តិទោសឧក្រិដ្ឋមុនពេលចាប់សកម្មភាពការងារ<br>- ការត្រួតពិនិត្យជាមួយអ្នកធានាដោយសម្ភាសផ្ទាល់មាត់<br>**តួនាទីដែលធ្វើការផ្ទាល់ជាមួយកុមារ**<br>វិធានបន្ថែមសម្រាប់សម្រាំងបុគ្គលិក(ដូចជាផែនការសម្ភាសន៍មានសំណួរត្រួតពិនិត្យអាកប្បកិរិយា) ត្រូវតែប្រើជាដាច់ខាតសម្រាប់បុគ្គលិកទាំងអស់ដែលធ្វើការជាមួយកុមារ។ | - ឯកសារបង្ហាញពីការស្នើឱ្យអ្នកដាក់ពាក្យធ្វើការបង្ហាញថាតើពួកគេធ្លាប់បានចោទប្រកាន់ពីបទកេងប្រវ័ញ្ច ឬបំពានលើកុមារ ព្រមទាំងការឆ្លើយតបរបស់ពួកគេ។<br>- ផែនការសម្ភាសន៍មានរួមបញ្ចូលសំណួរវាស់ស្ទង់អាកប្បកិរិយា ដែលជាក់លាក់ចំពោះមុខតំណែងដែលពាក់ព័ន្ធនឹងការធ្វើការជាមួយកុមារ។<br>- ក្នុងកាលៈទេសៈខ្លះ ការពិនិត្យកំណត់ត្រាព្រហ្មទណ្ឌដែលអាចទុកចិត្តមួយអាចមិនកើតឡើង។ នោះគួរតែអាចទទួលយកជំនួសបានដោយ សេចក្តីប្រកាសផ្នែកច្បាប់ ឬផ្នែកច្បាប់មូលដ្ឋានដែលសមមូលសេចក្តីបង្ហាញពីការខិតខំប្រឹងប្រែងដើម្បីបានការបញ្ជាក់ពីប៉ូលីសបរទេស និងសេចក្តីប្រកាសពីការចោទប្រកាន់និងការផ្តន្ទាទោសដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចលើកុមារ ។<br>ការត្រួតពិនិត្យត្រូវធ្វើក្នុងប្រទេសនីមួយៗដែលបុគ្គលធ្លាប់បានរស់នៅរយៈពេល១២ | ដំណើរការជ្រើសរើសនិងសម្រាំងបុគ្គលិកដែលធានាសុវត្ថិភាពកុមារអាចបង្អាក់ដល់បុគ្គលដែលអាចបង្កហានិភ័យចំពោះកុមារអោយដកថយពីការដាក់ពាក្យសុំមុខតំណែង។ | មនុស្សដែលអាចបង្កគ្រោះថ្នាក់ដែលមិនអាចទទួលយកបាន ដល់កុមារ (ដូចដែលបានបង្ហាញដោយសាវតារបស់ពួកគេ) ត្រូវបានតែងតាំងអោយកាន់មុខតំណែងក្នុងអង្គការ ដោយអ្នកមិនបានដឹងជាមុន។ |

| តម្រូវការ | ស្តង់ដាអប្បបរមា | ស្តង់ដាអប្បបរមា – ភស្តុតាង | ហេតុអ្វីតម្រូវបែបនេះ? | បើគ្មានវាទេ តើមានហានិភ័យអ្វីខ្លះកើតឡើង? |
|---|---|---|---|---|
| | | ខែឬ យូរជាងនេះ ក្នុងកំឡុងពី៥ឆ្នាំ និងប្រទេសជាតិខ្លួនផងដែរ។ | | |
| | 9.<br><br>អង្គការនេះមានក្រមសីលធម៌ការពារកុមារដែលគោរពតាម (និងបំពេញបន្ថែមតាមការចាំបាច់) បទដ្ឋានអប្បបរមាដែលកំណត់ដោយ DFAT (សូមមើលឯកសារភ្ជាប់B - អាកប្បកិរិយាវិជ្ជាជីវៈដើម្បីការពារកុមាររបស់DFAT)។ | ក្រមប្រតិបត្តិការពារកុមារផ្អែកលើហានិភ័យ អនុលោមតាមអាកប្បកិរិយាវិជ្ជាជីវៈដើម្បីការពារកុមាររបស់DFAT- ( DFAT's Child Protection –Professional Be-haviours )<br>ក្រមសីលធម៌ដែលបានចុះហត្ថលេខាឬឯកសារលំអិតអំពីបុគ្គលិកដែលបានចុះហត្ថលេខាលើក្រមការងារឬការដាក់បញ្ចូលក្នុងកិច្ចសន្យាការងារ<br><br>- **សេចក្តីមានចុះហត្ថលេខាលើ**សំណុំបែបបទយល់ព្រមលើគោលការណ៍រូបភាព / ឯកសារបញ្ជាក់យល់ព្រម | ក្រមសីលធម៌អង្គការបានបញ្ជាក់ច្បាស់ពីបទដ្ឋានរបស់អង្គការលើឥរិយាបទដែលអាចទទួលយកបាន និងមិនអាចទទួលយកបានទាក់ទងនឹងកុមាររួមទាំងការប្រើប្រាស់រូបភាព ហើយចាំបាច់ត្រូវតែចុះហត្ថលេខាដោយបុគ្គលទាំងអស់។<br><br>វាការពារបុគ្គលដោយអោយដំបូន្មានពីរបៀបជៀសវាងស្ថានភាពដែលរាប់ចូលថាបង្កគ្រោះភ័យលើកុមារ។<br><br>វាក៏អោយបុគ្គលិកដឹងថាទង្វើបែបណាដែលនឹងត្រូវរងពិន័យ។ | កង្វះភាពច្បាស់លាស់ និងការផ្សព្វផ្សាយល្អអាចបណ្តាលអោយកង្វល់នៃការប្រព្រឹត្តិអាកប្បកិរិយាមួយចំនួនក្លាយជារឿងសាមញ្ញទៅវិញ។<br>ការកំណត់អត្តសញ្ញាណ និងទីកន្លែងរស់នៅរបស់កុមារ។ |

## ឧបសម្ព័ន្ធ «ង»៖ ទំនាក់ទំនងលម្អិតសម្រាប់ធ្នាក់ងារការពារកុមារក្នុងប្រទេសកម្ពុជា

| អង្គភាព | ទំនាក់ទំនងលំអិត | ករណីបញ្ជូន |
|---|---|---|
| អង្គការទស្សនៈឥតព្រំដែន | មន្ត្រីការពារកុមារ និងបរិយាប័ន/ជនបង្គោលបង្ការហានីភ័យ<br>លោកស្រី តាន់ គិមឡេន<br>kimlen@seebeyondborders.org<br>នាយកប្រតិបត្តិអង្គការ<br>Mr. Ed Shuttleworth<br>ed@seebeyondborders.org<br>ឬ<br>feedback@seebeyondborders.org | អ្នកដែលត្រូវទាក់ទងដំបូងសំរាប់ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការទស្សនៈឥតព្រំដែន។ |
| លេខទូរស័ព្ទបន្ទាន់ការពារកុមារ (http://thinkchildsafe.org/hotline/) | 012 311 112 (ភ្នំពេញ)<br>017 358 758 (សៀមរាប)<br>092 911 115 (បាត់ដំបង)<br>childsafe@friends-internaitonal.org | ធ្វើការជាមួយបណ្តាញអង្គការដើម្បី ផ្តល់សេវាបញ្ជូនគ្រប់បញ្ហា និងការរំលោភបំពានលើកុមារ។ |
| លេខបន្ទាន់ប៉ូលីសថ្នាក់ជាតិ | 1288<br>023997919 | ករណីសង្ស័យនៃការរំលោភបំពាន ឬជួញដូរមនុស្ស។ |
| លេខទូរស័ព្ទជំនួយកុមារកម្ពុជា (http://childsafehelpline.org.kh/en/) | 1280<br>017 985 810 (ហៅដោយឥតគិតលុយ) | អ្នកជំនាញប្រឹក្សាតាមទូរស័ព្ទ ផ្តល់សេវាព័ត៌មាន បញ្ជូនតាមដានករណីពាក់ព័ន្ធនិងកុមារ។ |

**សេចក្តីប្រកាស អំពីការយល់ និងការអនុវត្តតាម**

ខ្ញុំឈ្មោះ....................................... (សរសេរឈ្មោះ) សូមប្រកាសថាខ្ញុំបានអាន ហើយយល់ច្បាស់អំពីគោលនយោបាយការពារកុមារ និងជនងាយរងគ្រោះ ក្រមសីលធម៌ របស់អង្គការទស្សនៈឥតព្រំដែនក្នុងការធ្វើការជាមួយកុមារ ហើយខ្ញុំទទួលស្គាល់ថាវាជាទំនួលខុសត្រូវរបស់ខ្ញុំក្នុងការអនុវត្តតាម ដូចមានចែងច្បាស់ក្នុង ឧបសម្ព័ន្ធ ក ។

ហត្ថលេខា......................................................................... កាលបរិច្ឆេទ...........................................

តួនាទី/សមាគម.......................................................................................................................